October-2007 I.qxd 10/23/2007 2:08 PM Page 1

CSC
ប្រព័ន្ធផ្សព្វផ្សាយព័ត៌មានកាតូលិក
ទូរស័ព្ទ: ០២៣ ២២៤ ១២០

# អ្នកនាំសារ
The Messenger

០៣

ឆ្នាំទី១ ថ្ងៃទី០១-៣០ តុលា ២០០៧- ច្បាប់អនុញ្ញាតរបស់ក្រសួងព័ត៌មានលេខ ១៨៣ ពមប្រក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ ២០០៧

## មាតិកាសំខាន់ៗ




បុណ្យភ្ជុំរបស់ព្រះសហគមន៍ !

ទំព័រ ៤



អ្នកជំងឺអេដស៍ភ្នំវល្លិ រីករាយនឹងជីវិតថ្មី

ទំព័រ ៩

សាររបស់សម្តេចប៉ាបបេណេឌីកទី១៦

ទំព័រ ១០


# អ្នកជំងឺអេដស៍ត្រូវការថ្នាំពន្យាជីវិតជាចាំបាច់



ទំព័រទី៦...






យានដ្ឋាន For you
for you Garage
មានទទួលជួសជុលរថយន្តគ្រប់ប្រភេទ
All Kinds of Repairing Services
សូមមេត្តាជួយផ្តល់ឱកាសដល់យុវជនក្រីក្រដែលគ្មានលទ្ធភាពទទួលការអប់រំនៅសាលា។ សូមអរគុណ!
Tell: 012 377 460 E-mail: philong2007@gmail.com
អាសយដ្ឋាន : ផ្លូវជាតិលេខ ៥ គីឡូម៉ែត្រលេខ ៨

កម្មវិធីវិទ្យុ



អេម៉ានូអែល សំឡេងពីព្រះសហគមន៍កាតូលិក !
ភ្នំពេញ : FM 99.5 Mhz ម៉ោង ៧:០០-៧:៣០ រាល់យប់ថ្ងៃសៅរ៍ ។
បាត់ដំបង : FM 91.0 Mhz ម៉ោង ៧:៣០-៨:០០ រាល់យប់ថ្ងៃសៅរ៍ ។
កំពង់ធំ : FM 107.3 Mhz ម៉ោង ៥:៣០-៦:០០ រាល់ល្ងាចថ្ងៃសៅរ៍ ។
កំពង់ចាម : FM 100.5 Mhz ម៉ោង ៩:៣០-១០:០០ យប់ថ្ងៃអាទិត្យ ។
ក្រុងព្រះសីហនុ : FM 100.5 Mhz ម៉ោង៧:៣០-៨:០០ យប់ថ្ងៃសៅរ៍ ។

October-2007 I.qxd 10/23/2007 2:09 PM Page 2



# ហេតុអ្វីព្រះសហគមន៍យកចិត្តទុកដាក់ជួយអ្នកជំងឺអេដស៍?


Photo: DR

តាមទិន្នន័យពីអង្គការ KHANA បង្ហាញថា : “កម្ពុជាជាប្រទេសដែលមានការឆ្លងជំងឺអេដស៍ខ្លាំងជាងគេក្នុងតំបន់អាស៊ីអាគ្នេយ៍។ ទោះបីជាមានការធ្លាក់ចុះនៃអត្រាអ្នកផ្ទុកមេរោគអេដស៍ពី ៣,៣% នៅឆ្នាំ១៩៩៨ មកត្រឹម ១,៦% នៅឆ្នាំ២០០៦ក្តី ក៏សព្វថ្ងៃមានប្រជាជនកម្ពុជាច្រើនជាង ២៥០ ០០០នាក់ មានផ្ទុកមេរោគអេដស៍ និងប្រមាណ ៩៤ ០០០នាក់ បានទទួលមរណភាពរួចមកហើយ។ ព្រះសហគមន៍កាតូលិក បានប្តេជ្ញាចិត្តយ៉ាងខ្លាំងក្នុងការជួយគាំពារ និងយកចិត្តទុកដាក់ចំពោះអ្នកជំងឺអេដស៍តាមរយៈកម្មវិធីផ្សេងៗពីក្រុមបងស្រីមេត្តាករុណា អង្គការម៉ារីណុល និងអង្គការការីតាសកម្ពុជាជាដើម។ លោកអ្នកប្រហែលមានចម្ងល់ថា : “ហេតុអ្វីបានជាព្រះសហគមន៍កាតូលិកយកចិត្តទុកដាក់ចំពោះអ្នកផ្ទុក និងអ្នកជំងឺអេដស៍ម្ល៉េះ ?”

ជាបឋម យើងខ្ញុំសូមជម្រាបថា គ្រីស្តសាសនាជាជាក់ស្តែង ឱ្យតម្លៃបុគ្គលម្នាក់ៗ និងផ្តល់កិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយសារមនុស្សទាំងអស់គ្នា មានតម្លៃមិនអាចគណនា ដែលនេះជាការប្រទានពីព្រះជាម្ចាស់។ ដូច្នេះហើយព្រះសហគមន៍កាតូលិក បានបដិសេធយ៉ាងដាច់អហង្ការចំពោះការរើសអើង និងអំពើហិង្សាប្រឆាំងអ្នកផ្ទុក និងអ្នកជំងឺអេដស៍។ នេះជាអំពើអយុត្តិធម៌ និងអសីលធម៌។

បន្ទាប់មកទៀត តាមការប្រៀនប្រដៅរបស់គ្រីស្តសាសនា សង្គមនីមួយៗត្រូវចេះទទួលខុសត្រូវចំពោះបញ្ហាមនុស្សដែលកើតមានឡើង។ ដូច្នេះព្រះសហគមន៍កាតូលិក បានបញ្ជាក់នូវសេចក្តីត្រូវការដើម្បីឱ្យមានសាមគ្គីភាពនៅក្នុងសង្គមនីមួយៗ ដោយសេចក្តីមេត្តាករុណាដល់អ្នកជំងឺ។ ដូច្នេះយើងត្រូវផ្តល់ការថែទាំ ទាំងកម្លាំងកាយ-ចិត្ត និងជួយផ្តល់ថ្នាំពេទ្យដើម្បីឆ្លើយតបសេចក្តីត្រូវការរបស់អ្នកជំងឺ។ ក្រោយបង្អស់គ្រីស្តសាសនាជឿថា សេចក្តីស្រលាញ់របស់ព្រះជាម្ចាស់មានទំហំធំធេងរកអ្វីប្រៀបផ្ទឹមមិនបានឡើយ។ អាកប្បកិរិយារបស់ព្រះសហគមន៍ចំពោះអ្នកជំងឺអេដស៍ គឺផ្អែកលើសេចក្តីស្រឡាញ់ដ៏គ្មានព្រំដែនពីព្រះជាម្ចាស់ មិនមែនរិះគន់ការប្រព្រឹត្តរបស់ពួកគេទេ។ ចម្លើយតបរបស់យើងចំពោះបញ្ហាជំងឺអេដស៍ មិនគ្រាន់តែជាថ្នាំពេទ្យឡើយ ក៏ប៉ុន្តែជាសេចក្តីពិតដែលជាព្រះអំណោយទានពីព្រះជាម្ចាស់។

**លោកបូជាចារ្យអូមែរ ហ្សឺរ៉ាល់ដូ**



# កិច្ចប្រជុំរបស់អង្គការ ស៊ីកនីស អាស៊ី










Photographed by L. Sovanna

**ស៊ីកនីស(Signis)** ជាឈ្មោះអង្គការកាតូលិកក្រៅរដ្ឋាភិបាលដែលបានបង្កើតឡើងតាំងពីឆ្នាំ២០០១ ដែលក្នុងនោះ មានសមាជិកទាំងអស់ចំនួន ១៤០ ប្រទេសនៅជុំវិញពិភពលោកទាំងមូល ។

អង្គការនេះ មានគោលដៅបង្ហាញពីតម្លៃនៃទ្រឹស្តីគ្រីស្តសាសនា ដោយការគោរពរបស់គ្រីស្តបរិស័ទចំពោះសាសនាផ្សេងៗ និងប្រកាសដំណឹងល្អតាមវប្បធម៌នៃប្រទេសនីមួយៗ តាមរយៈការបង្កើតកម្មវិធីវិទ្យុ វីដេអូ និងកម្មវិធីទូរទស្សន៍-ល- ។

សម្រាប់អង្គការស៊ីកនីស អាស៊ី ដែលជាសមាជិកស៊ីកនីសពិភពលោក ក៏បានយកចិត្តទុកយ៉ាងខ្លាំងក្លាផងដែរ ក្នុងការកសាងសន្តិភាព តាមរយៈការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ ។

ជាក់ស្តែងនៅក្នុងអង្គសន្និបាតស៊ីកនីសអាស៊ី ដែលប្រព្រឹត្តទៅរយៈពេល ៥ថ្ងៃ គឺពីថ្ងៃទី២៥ ដល់២៩ កញ្ញាកន្លងទៅ នៅក្នុងក្រុងតូក្យូ ប្រទេសជប៉ុន ក៏បានរិះគិតពីប្រធានបទ : **“សំឡេងជាច្រើនដើម្បីបេសកកម្មតែមួយគឺសន្តិភាព”** ផងដែរ ។

តាមរយៈអង្គសន្និបាត ក៏មានការជំរុញឱ្យប្រទេសនីមួយៗជាសមាជិកក្នុងតំបន់ យកចិត្តទុកដាក់ប្រើប្រព័ន្ធផ្សព្វផ្សាយ ដោយត្រឹមត្រូវ តាមគោលដៅដើម្បីសន្តិភាពស្របតាមទ្រឹស្តីនៃគ្រីស្តសាសនា ។

អង្គសន្និបាតបានបង្កើតជាប្រព័ន្ធអ្នកព័ត៌មានក្នុងតំបន់ដើម្បីជួយគ្នាទៅវិញទៅមកទៀតផងដែរ ។

សូមបញ្ជាក់ដែរថា អង្គសន្និបាតនេះ មានប្រទេស ១៣ ចូលរួម និងមានសមាជិកចំនួន ៥២នាក់ ។





# ការបញ្ជូនកូនទៅសាលារៀនជាកាតព្វកិច្ចរបស់មាតាបិតាគ្រប់ៗរូប

បវេសនកាលនៃឆ្នាំសិក្សា២០០៧-២០០៨ បានឈានចូលមកដល់ហើយ ។ សម្រាប់ប្អូនៗ កុមារដែលមានអាយុគម្រប់ ៦ឆ្នាំ ឪពុកម្តាយ ឬមួយក៏អាណាព្យាបាល ត្រូវនាំពួកគេទៅចុះឈ្មោះចូលរៀនក្នុងឆ្នាំសិក្សាថ្មីនេះឱ្យបានគ្រប់ៗគ្នា ។

សិទ្ធិទទួលបាននូវការអប់រំ ជាសិទ្ធិមួយដែលស្ថិតនៅក្នុងចំណោមសិទ្ធិទាំង៤ របស់កុមារដែលមានចែងជាសកលស្តីអំពីសិទ្ធិកុមារ ហើយក៏ត្រូវបានទទួលការគាំទ្រ ដោយច្បាប់រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជាផងដែរ ។

វិស័យអប់រំ គឺត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកថា ជាវិស័យអត្ថិភាពចំបងមួយ ដែលឋិតក្នុងចំណោមវិស័យអត្ថិភាពជាច្រើន ហើយដែលមាននៅក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាលផងដែរ ។ វិស័យនេះក៏ទទួលបាននូវការយកចិត្តទុកដាក់អំពីសំណាក់ប្រមុខនៃរាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍឱ្យបានល្អប្រសើរផងដែរផងដែរ ។

លោកទេព ផល្លឿន ជានាយករងនៃសាលាបឋមសិក្សាច្រាំងចំរេះ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ មានប្រសាសន៍ថា សម្រាប់ឆ្នាំសិក្សាថ្មីនេះសិស្សដែលបានចុះឈ្មោះ ចូលរៀនថ្នាក់ទី១ មានចំនួន ១៨៩នាក់ បើគិតជាភាគរយ មានប្រមាណជាង ៧០ភាគរយ គិតមកដល់ត្រឹម ថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៧ ដែលតាមគម្រោង ចំនួនសិស្សដែលសាលារបស់លោកត្រូវការទាំងអស់ គឺមាន៣០០ នាក់ ។ លោកបន្ថែមទៀតថា ការចុះឈ្មោះមានការកើនឡើងបន្តទៀត នៅចុងខែកញ្ញា និងដើមខែតុលា ដែលជាពេលវេលាដែលសាលារៀនចាប់ផ្តើមបើកបវេសនកាលថ្មី តួយ៉ាង បវេសនកាលនៅឆ្នាំសិក្សា២០០៧-២០០៨ នេះ ។

សម្រាប់ឆ្នាំសិក្សានេះ ការចុះឈ្មោះចូលរៀនបានប្រព្រឹត្តទៅដោយរលូន ដោយសារមានការចូលរួមជួយផ្សព្វផ្សាយពីប្រព័ន្ធផ្សព្វផ្សាយនានា ដូចជាតាមរយៈកាសែត ទូរទស្សន៍ វិទ្យុ-ល- ហើយ និងមានការជួយជ្រោមជ្រែងពីសំណាក់អង្គការ


Photo: S. Philong

អាជ្ញាធរដែនដី រួមនិងការយល់ដឹងរបស់អាណាព្យាបាល ឬឪពុកម្តាយសិស្សផងដែរ ។

ជាចុងក្រោយដែរ លោកនាយករងសាលារូបនេះ បានសំណូមពរដល់មាតាបិតាទាំងអស់ សូមយកកូន ដែលគ្រប់អាយុចូលរៀន ទៅចុះឈ្មោះចូលរៀនឱ្យបានរួសរាន់ គ្រប់ៗគ្នា និងទាន់ពេលវេលានៃការបើកបវេសនកាលសម្រាប់ឆ្នាំសិក្សានេះ ។ ចំពោះសិស្សចាស់ សូមមាតាបិតាជួយដាស់តឿនកូនឱ្យទៅរៀនសូត្រឱ្យបានទៀងទាត់ពេលវេលាជៀសវាងកុំឱ្យមានអវត្តមានច្រើន ។

កំពុងសុំចុះឈ្មោះឱ្យកូនស្រីចូលរៀនថ្នាក់ទីមួយ អ្នកស្រីមាន ចន្ទ ដែលជាប្រជាពលរដ្ឋរស់នៅក្នុងសង្កាត់ឫស្សីកែវ មានប្រសាសន៍ ឱ្យដឹងដែរថា : "ឆ្នាំនេះ កូនស្រីខ្ញុំមានអាយុ ៦ឆ្នាំហើយ ហើយខ្ញុំមានបំណងចុះឈ្មោះឱ្យនាងបានចូលរៀននៅឆ្នាំសិក្សានេះផងដែរ ។" អ្នកស្រីបន្ថែមទៀតផងថា កន្លងមកអ្នកស្រីធ្លាប់បានបញ្ជូនកូន ឱ្យចូលរៀននៅថ្នាក់មត្តេយ្យនៅតាមសាលាឯកជនពី ២ ទៅ ៣ឆ្នាំដែរ ។ អ្នកស្រីចន្ទ បន្តទៀតថា អ្នកស្រីមានបំណងឱ្យកូនអ្នកស្រី បានទទួលចំណេះដឹងនឹងគេ ហេតុដូច្នេះហើយ ទើបអ្នកស្រីបញ្ជូននាង ឱ្យទៅរៀន ម្យ៉ាងទៀត ការបញ្ជូនកូនឱ្យចូលរៀន គឺជាកាតព្វកិច្ចរបស់មាតាបិតាគ្រប់ៗរូបដែលត្រូវតែអនុវត្ត ។ អ្នកស្រីសប្បាយរីករាយ នៅពេលដែលកូនអ្នកស្រីចាប់ផ្តើមរៀនអំពីការទំនាក់ទំនង ជាមួយមិត្តភក្តិថ្មីនៅឯសាលារៀន ក៏ដូចជា នៅក្នុងសង្គម ។ "ភាពអវិជ្ជា នឹងលែងមានទៀតហើយនៅក្នុងខ្លួនកូនខ្មែរ ហើយក៏ពុំមានការមើលងាយពីប្រទេសជិតខាងដែរ ប្រសិនបើពួកគេខិតខំប្រឹងប្រែងរៀនសូត្រ ។" នេះជាក្តីសង្ឃឹមអ្នកស្រីចន្ទ ។

តាមមតិរបស់អ្នកជំនាញជាច្រើនក្នុងវិស័យអប់រំ បានឱ្យដឹងដែរថា ក្មេងដែលបានឆ្លងកាត់មត្តេយ្យសាលាមួយឆ្នាំ ឬពីរឆ្នាំ មុនចូលរៀនថ្នាក់ទីមួយ មានការសិក្សាល្អជាងក្មេងដែលមិនបានចូលរៀនថ្នាក់មត្តេយ្យជាមុននោះ ។ តាមធម្មតាក្មេងដែលបានរៀនក្នុងមត្តេយ្យសាលា ពួកគេបានចាប់ផ្តើមរៀនហាត់ពត់សំឡេង ក្នុងការអាន រៀនសរសេរ និងប្រើសរីរាង្គកាយទាំងមូលរបស់ខ្លួន ហើយជាពិសេស ពួកគេបានរៀនទំនាក់ទំនងជាទូទៅ ជាមួយនឹងមជ្ឈដ្ឋានខាងក្រៅពីសង្គមគ្រួសារ ។សូមបញ្ជាក់ថា ក្មេងដែលអាចចូលរៀនថ្នាក់មត្តេយ្យត្រូវមានអាយុចាប់ពី ៣ឆ្នាំ រហូតដល់ ៥ឆ្នាំ ។

**ឡុង សម្ផស្ស**






Photo: HIB

# ច្បាប់ ! ចរាចរណ៍ផ្លូវគោក

**សេដ្ឋកិច្ចសង្គមកាន់តែរីកចម្រើនទៅមុខ ចំនួនប្រជាជន និងយានយន្តប្រើប្រាស់ផ្លូវថ្នល់កើនមិនឈប់ឈរ ធ្វើឱ្យបញ្ហាចរាចរណ៍ចោទជាបញ្ហាប្រឈមដ៏ធ្ងន់ធ្ងរ។ ដើម្បីចូលរួមចំណែកកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ អ្នកនាំសារ សូមចុះផ្សាយច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកនៃព្រះរាជាណាចក្រកម្ពុជាដូចតទៅ :**

ពាក្យថា **ផ្លូវប្រសព្វ** គឺជាទីកន្លែងប្រសព្វនៃផ្លូវពីរ ឬច្រើនដែលមានផ្ទៃរាបតែមួយ និងមិនកំណត់មុំនៃអ័ក្សរបស់ទ្រូងផ្លូវឡើយ ។ ផ្លូវប្រសព្វអាចមានរាងជា +, X, T, Y ឬរង្វង់មូលជាដើម

ពាក្យថា **ផ្លូវរង្វង់មូល** គឺជាកន្លែងប្រសព្វនៃផ្លូវពីរ ឬច្រើន ហើយដែលនៅចំកណ្តាល មានខឿន រូបសំណាក ឬវិមានផ្សេងៗ និងមានទ្រូងផ្លូវឯកទិសព័ទ្ធជុំវិញដោយមានសញ្ញាព្រួញប្រាប់ទិសចរាចរណ៍

ពាក្យថា **ផ្លូវសាធារណៈ** គឺជាផ្លូវសម្រាប់បើកឱ្យធ្វើចរាចរណ៍ទូទៅជាសារធារណៈ

ពាក្យថា **ផ្លូវឯកជន** គឺជាផ្លូវកសាងដោយឯកជន ដែលចែកចេញជា ២ប្រភេទ ដូចខាងក្រោម :

ក-ផ្លូវឯកជនបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈ គឺជាផ្លូវបើកឱ្យធ្វើចរាចរណ៍ទូទៅ ដែលបានសាងសង់ ឬជួសជុលដោយឯកជនតាមកិច្ចសន្យាជាមួយរដ្ឋ ។

ខ-ផ្លូវឯកជនមិនបើកឱ្យធ្វើចរាចរណ៍ជាសាធារណៈ គឺជាច្រកផ្លូវសម្រាប់បម្រុងទុកបម្រើការងារក្នុងទីបរិវេណណាមួយ ដូចជាច្រកគេហដ្ឋាន រោងចក្រ សហគ្រាស អគារ ឬទីលានបរិវេណផ្សេងៗ ។

ពាក្យថា **ផ្លូវលំ** គឺជាផ្លូវដីដែលតភ្ជាប់ពីផ្លូវជាតិ ឬផ្លូវខេត្តឆ្ពោះទៅភូមិ ឬឃុំនៅជនបទ

-ពាក្យថា **ឈប់** គឺជាការនៅស្ងៀមនៃយានជំនិះលើទ្រូងផ្លូវមួយរយៈពេលចាំបាច់ ដែលមានអ្នកបើកបរស្ថិតនៅជាប់នឹងចង្កូត ឬក្បែរយានជំនិះខ្លួន ដើម្បីឱ្យអ្នកដំណើរ ឬយានជំនិះដទៃទៀតឆ្លងកាត់ ឬដើម្បីអែបខាងដាក់ទំនិញ ឬអ្នកដំណើរឡើងចុះ

**សូមរង់ចាំលេខក្រោយ...**

**ពិធីបុណ្យភ្ជុំ គឺជាប្រពៃណីខ្មែរដែលមានតាំងពីយូរយារណាស់មកហើយ។ ពុទ្ធបរិស័ទប្រារព្ធពិធីនេះនៅក្នុងវត្តអារាម ចំណែកគ្រីស្តបរិស័ទប្រារព្ធធ្វើនៅតាមព្រះវិហារកាតូលិក។ តើក្នុងពិធីបុណ្យភ្ជុំ ព្រះសហគមន៍ ឬគ្រីស្តបរិស័ទបានរៀបចំធ្វើអ្វីខ្លះ?**

# បុណ្យភ្ជុំនៅក្នុងព្រះសហគមន៍!





លោកបូជាចារ្យបប់ ពិសេ ដឹកនាំពិធីបុណ្យភ្ជុំតាមរបៀបព្រះសហគមន៍

Photo: L. Sovanna

លោកបូជាចារ្យឆាត់ឆ័យ នៃព្រះសហគមន៍កាតូលិក សន្តយ៉ូសែប ផ្សារតូច-រាជធានីភ្នំពេញ បានធ្វើការបកស្រាយចំពោះចំនុចនេះថា នៅក្នុងពិធីបុណ្យភ្ជុំ ព្រះសហគមន៍កាតូលិក មានការរៀបចំដូចគ្នានឹងបងប្អូនខាងពុទ្ធបរិស័ទដែរ។ បងប្អូនគ្រីស្តបរិស័ទយើងមានថ្ងៃមួយ ដែលយើងនឹកអំពីបុណ្យរំឭកវិញ្ញាណក្ខន្ធ គឺនៅថ្ងៃទី២ នាខែវិច្ឆិកា តែដោយសារបងប្អូនខ្មែរទូទាំងប្រទេសបានរំឭកវិញ្ញាណក្ខន្ធជីដូន-ជីតា ដែលគេហៅថាបុណ្យភ្ជុំបិណ្ឌនោះ ដូច្នេះព្រះសហគមន៍កាតូលិក បានលើកយកថ្ងៃនោះមករៀបចំជាមួយបងប្អូនពុទ្ធបរិស័ទខ្មែរតែម្តង។ សម្រាប់ពិធីបុណ្យដែលយើងធ្វើ គឺយើងមិនមានបិណ្ឌទេ ដូច្នេះពាក្យហៅ ក៏អាចមានការខុសគ្នាដែរជាមួយនឹងបងប្អូនពុទ្ធបរិស័ទ ដោយព្រះសហគមន៍កាតូលិកហៅថា "បុណ្យភ្ជុំ"។ បុណ្យភ្ជុំ ជាបុណ្យដែលយើងរួបរួមគ្នា ផ្តុំគ្នា ហើយការជួបជុំគ្នានេះមិនមែនតែបងប្អូនយើង នៅលើលោកនេះទេ។ បើតាមគំនិតខាងទេវវិទ្យា គឺយើងមានបីឋាន ដែលឋានទី១ គឺឋានបរមសុខ ដែលនៅទីនោះ មានព្រះយេស៊ូ ព្រះនាងម៉ារី និងសន្តបុគ្គលទាំងឡាយដែលបានស្លាប់។ អ្នកទាំងនោះមានបុណ្យ ត្រូវព្រះជាម្ចាស់ទទួល។ ចំពោះឋានកណ្តាល ជាឋាននៅលើលោកីយ៍នេះ ដែលមានបងប្អូនរស់នៅជាមួយគ្នា។ ឋាននេះគឺសំដៅទៅលើឋាន ដែលមានបងប្អូនដែលមានជីវិតរស់នៅ។ ចំណែកឯឋានទី៣ វិញនោះគឺឋានក្រោមជាឋាន ដែលទុកសម្រាប់ជាយាន ដែលត្រូវការជម្រះនូវអំពើបាបដែលមនុស្សធ្វើនៅពេលគាត់មានជីវិត។ ហេតុដូច្នេះយើងត្រូវរំឭកទាំង៣ឋាននេះ នៅក្នុងពិធីបុណ្យភ្ជុំនេះតែម្តង។

### អត្ថន័យនៃការយកអាហារទៅព្រះវិហារ

**ចំពោះការយកអាហារ និងនំចំណីទៅកាន់ព្រះវិហារ លោកបូជាចារ្យបានឱ្យដឹងអំពីអត្ថន័យនេះថា សម្រាប់អាហារនំចំណីទាំងនោះ ដូចជាឧបករណ៍ម្យ៉ាង ព្រោះជាធម្មតាមនុស្សតែងតែយកពិធីជប់លៀង ឬការហូបចុកជាឱកាសមួយសម្រាប់ឱ្យយើងធ្វើការសំណេះសំណាលគ្នា និងសួរសុខទុក្ខគ្នាទៅវិញទៅមក ឬឱ្យយើងចេះរួបរួមសាមគ្គីគ្នាជាធ្លុងតែមួយ។**

សម្រាប់ព្រះសហគមន៍កាតូលិកនៅប្រទេសកម្ពុជាយើង មានការរៀបចំនៅតាមបណ្តាព្រះសហគមន៍ផ្សេងៗ ដោយព្រះសហគមន៍ទាំងនោះ មានធ្វើការរៀបចំ ដូចបងប្អូនពុទ្ធបរិស័ទដែរ ដោយមានការរៀបចំធ្វើ ជាបាយ-សម្លនិងម្ហូបអាហារជាមួយគ្នានៅតាមថ្ងៃនីមួយៗ។ រហូតដល់ថ្ងៃចុងក្រោយនៃពិធីបុណ្យនោះ យើងធ្វើការរំឭកទៅដល់ឋានទាំង៣ នោះតែម្តង។

ដូច្នេះពិធីនៅក្នុងថ្ងៃបុណ្យភ្ជុំនោះ គឺទីមួយ យើងធ្វើពិធីថ្វាយអភិបូជាដើម្បីរំឭកដល់សន្តបុគ្គលទាំងឡាយ ដែលនៅពេលនោះយើងមានរួមគ្នាថ្វាយបង្គំព្រះជាម្ចាស់ និងលើកតម្កើងព្រះជាម្ចាស់រួមជាមួយសន្តបុគ្គលដែលបានរួមជាមួយនឹងព្រះយេស៊ូ ព្រះបិតានិងព្រះវិញ្ញាណដ៏វិសុទ្ធនៅឯឋានបរមសុខ។ ក្រោយមកយើងជួបជុំគ្នានៅជុំវិញចេតិយ ឬដីព្រះពរ (ជាទីបញ្ចុះសព) ដើម្បីប្រសិទ្ធពរទៅដល់វិញ្ញាណក្ខន្ធសពនៅទីនោះ និងធ្វើការអធិដ្ឋានឱ្យបងប្អូន ដែលស្ថិតនៅឋានក្រោម ដោយអង្វរករព្រះជាម្ចាស់ដើម្បីឱ្យមកទទួលយកវិញ្ញាណក្ខន្ធទាំងនោះ និងសូមឱ្យលើកលែងទោសដល់វិញ្ញាណក្ខន្ធទាំងនោះឱ្យបានទៅរួមជាមួយព្រះអង្គផង។ ជាចុងក្រោយបង្អស់យើងមានការជួបជុំគ្នាដើម្បីហូបបាយរួមគ្នាជាក្រុមធំមួយ។

**អ្នកនាំសារ**



# របៀបនៃការដាំដំណាំស្ពៃក្តោប

**ស្ពៃក្តោបជាដំណាំមួយប្រភេទ ដែលប្រជាកសិករខ្មែរយើងនិយមដាំជាលក្ខណៈគ្រួសារ និងប្រកបអាជីវកម្មផងដែរ។ ជាមួយនេះក៏នៅមានប្រជាកសិករមួយចំនួនមិនទាន់បានដឹងច្បាស់ពីរបៀបដាំ និងការថែទាំធ្វើយ៉ាងណាឱ្យទទួលបានទិន្នផលខ្ពស់ផងដែរ។ នេះគឺជារបៀបដាំ និងថែរក្សាខ្លះៗសម្រាប់ប្រជាកសិកររបស់យើង។**



ដំណាំស្ពៃក្តោបដែលគេដាក់តាំងលក់នៅលើទីផ្សារស្រស់ៗ

Photo: S. Philong

**ការរៀបចំថ្នាល និងការសាបគ្រាប់**

កសិករត្រូវរៀបចំកាប់ដី និងជ្រុំពង្រាបដីឱ្យរាបស្មើ រួចលើកជារងដែលមានទទឹង ៨តឹក និងកម្ពស់ប្រហែល មួយតឹក។ បន្ទាប់មក គឺយកដីលាយជាមួយលាមកគោម៉ដ្តប្រហែល ២អម្រែក មករោយគ្របពីលើឱ្យស្មើល្អរួចជ្រុំលាយឱ្យសព្វនិងកៀរឱ្យស្មើគ្នាល្អ។ គ្រាប់ស្ពៃក្តោប ដែលយកមកសាប ត្រូវត្រាំទឹក ១យប់ រួចផ្អាប់ ១យប់ ដើម្បីឱ្យគ្រាប់រីកឆាប់ដុះពន្លក។ ក្រោយពីត្រាំផ្អាប់ហើយ ត្រូវយកសាបឱ្យរង្វើលលើថ្នាល។ បន្ទាប់មកយកផេះចំបើងមករោយពីលើដើម្បីការពារស្រមោចនិងផ្តល់ជីវជាតិឱ្យដល់ដំណាំ។ យកធាងដូងមកគ្របពីលើរងដើម្បីការពារវា កុំឱ្យត្រូវកម្តៅថ្ងៃខ្លាំង ឬទឹកខ្លាំងពេលមានភ្លៀងធ្លាក់។ ដំណាំនេះត្រូវការដីដែលស្រស់ទឹកល្អ មានខ្យល់អាកាសចេញចូល និងពន្លឺគ្រប់គ្រាន់។ ត្រូវរៀបចំថ្នាលសាបកូនឱ្យបានល្អនិងរង្វើលៗដើម្បីបានកូនដំណាំថ្លោស សុខភាពល្អ និងកុំទុកកូនស្ពៃឱ្យចាស់ពេក ព្រោះកូនចាស់ធ្វើឱ្យស្ពៃក្តោបតូច។ ត្រូវចៀសវាងស្រោចទឹកល្អក់ (ប្រើប្រាស់ទឹកត្រពាំងដែលថ្លាល្អ) និងប្រើជីទឹកបំប៉នបន្ថែម ជាពិសេសជីកំប៉ុស្តទឹក។

**ការរៀបចំដីដាំ និងការដាំ**

ដីសម្រាប់ដាំស្ពៃក្តោប ត្រូវភ្ជួររាស់ឱ្យរាបស្មើ និងយកស្មៅចេញ។ បន្ទាប់មក លើកជារងៗ ដែលមានទទឹង ៨តឹក និងកម្ពស់ ១តឹក ឯបណ្តោយអាស្រ័យទៅតាមទំហំដី។ កាប់រណ្តៅ២ជួរ ឆ្លាស់គ្នា ដែលរណ្តៅនីមួយៗ មានទំហំប្រហែល ពីរតឹក បួនជ្រុង ហើយគម្លាតពីរណ្តៅ១ ទៅរណ្តៅ១ មានទំហំ ៦តឹក។ ក្នុងរណ្តៅនីមួយៗ ក៏ត្រូវដាក់ជីលាមកគោ ដែលពុកផុយល្អលាយជាមួយនឹងសំរាមស្លឹកឈើ និងដីដំបូកម៉ដ្តល្អឱ្យជិតពេញរណ្តៅ (លាមកគោ១ភាគ និងដីដំបូក ២ភាគ) បន្ទាប់មកត្រូវជ្រុំដីនិងជីឱ្យសព្វ។ មុននឹងដកកូនស្ពៃក្តោបយកទៅដាំ ត្រូវស្រោចទឹកវាឱ្យសើមជាមុនសិន ដើម្បីងាយស្រួលពេលគាស់កូនកុំឱ្យដាច់ឫស។ ត្រូវគាស់កូនស្ពៃឱ្យនៅជាប់ដីមុននឹងយកទៅដាំ។ ក្រោយពីដាំហើយ ត្រូវបង្ហាប់ដីឱ្យណែន (ពុំត្រូវកប់កូនរាក់ពេក ឬជ្រៅពេកទេ) បន្ទាប់មកត្រូវស្រោចទឹកឱ្យជោគ។

**ការថែទាំ**

បន្ទាប់ពីដាំរួច គួរតែយកធាងត្នោត ឬកូនរុក្ខជាតិមកគ្របការពារកម្តៅថ្ងៃ។ ត្រូវធ្វើការស្រោចទឹក ៣ដង ក្នុងមួយថ្ងៃ។ ក្រោយពីដាំបានរយៈពេល ១៥-២០ថ្ងៃ ត្រូវចាប់ផ្តើមជ្រោយដី និងធ្វើជើងលើកទី១ ហើយរោយជីកំប៉ុស្តនៅតាមចន្លោះរង។ បន្ទាប់ពីដាំបាន ២០ថ្ងៃ ចាប់ផ្តើមធ្វើជើងលើកទី២ ដោយបន្ថែមជី (ដីដំបូកលាយជាមួយលាមកគោ និងសំរាម) នៅតាមចន្លោះរង។

**សម្រង់ពីទស្សនាវដ្តីកសិករលេខ ៩៧**

### ធ្វើជីកំប៉ុស្តទឹក

**មានទន្រ្ទានខេត្តចំនួន ៣គីឡូ លាមកគោ ២គីឡូ និងទឹក ២០លីត្រ។ យកធាតុផ្សំទាំងអស់ទៅលាយបញ្ចូលគ្នាឱ្យសព្វ រួចយកទៅដាក់ក្នុងពាង ត្រាំទុករយៈពេល មួយសប្តាហ៍។ យកទឹកជី មួយលីត្រ លាយទឹកធម្មតាពី ៥-៦លីត្រស្រោចនៅតាមរងដំណាំពេលល្ងាច តែកុំឱ្យប៉ះស្លឹក។ ស្រោចជីទឹកនេះ១សប្តាហ៍ម្តង។ ពេលស្ពៃចាប់ផ្តើមក្តោប ត្រូវស្រោចទឹកឱ្យគ្រប់គ្រាន់។**



# ជំងឺវិកលចរិត

**ទោះបីជាវិទ្យាសាស្ត្រមានការរីកចម្រើនក្តី ប្រជាពលរដ្ឋនៅតែជួបប្រទះនូវបញ្ហាសុខភាពទាំងផ្លូវកាយ និងផ្លូវចិត្ត។ រីឯបញ្ហាសុខភាពផ្លូវចិត្តជាបញ្ហាធំពាក់ព័ន្ធនឹងជីវិតរស់នៅប្រចាំថ្ងៃរបស់មនុស្ស និងជាកង្វល់ដែលត្រូវដោះស្រាយ និងព្យាបាលឱ្យទាន់ពេលវេលា។**

ជំងឺវិកលចរិតជាប្រភេទជំងឺដែលឋិតនៅក្នុងផ្នែកជំងឺផ្លូវចិត្ត។ ជំងឺនេះស្តែងឡើងជារោគសញ្ញា ដូចជាអ្នកជំងឺគេងពុំលក់។ គាត់មានអារម្មណ៍ថា មានគេមកធ្វើបាប ដែលធ្វើឱ្យគាត់ភ័យខ្លាចជាដើម។ អ្នកស្រីចក ធីតា វេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា និងជាអនុប្រធានកម្មវិធីជាតិសម្រាប់សុខភាពផ្លូវចិត្ត នៅឯមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត មានប្រសាសន៍ថា: "ជំងឺទូទៅ យើងដឹងបានដោយធ្វើការពិនិត្យនៅលើរាងកាយពិនិត្យឈាម ឬថតឆ្លុះ។ ប៉ុន្តែជំងឺវិកលចរិតមានលក្ខណៈផ្ទុយ។ យើងអាចដឹងបាន ពីព្រោះឃើញអ្នកជំងឺ មានអាការៈប្តូរឥរិយាបថដូចជានៅសំងំស្ងៀម ខ្លាចមនុស្ស ឆាប់មួម៉ៅ និងគេងមិនលក់ មិនហូបបាយចំណីព្រោះខ្លាចគេបំពុល។ គាត់មិនសំអាតខ្លួន ជូនកាលកាច ឬរំខានគេឯងនៅជុំវិញខ្លួន-ល-។"

អ្នកស្រីវេជ្ជបណ្ឌិត បន្តទៀតថា មានកត្តាជាច្រើនដែលបណ្តាលឱ្យមានជំងឺនេះដូចជា កត្តាចិត្តសាស្ត្រ (អត្តចរិតពីកំណើត ក្នុងគ្រួសារគ្មានការយោគយល់គ្នា) កត្តាសង្គមសាស្ត្រ (ការផ្លាស់ប្តូរទីកន្លែងរស់នៅ ការទទួលរងនូវគ្រោះមហន្តរាយ ភ្លើងឆេះផ្ទះ ឬជួបរឿងរន្ធត់ ដូចជា មានចោរឆក់ ប្លន់...) ចំណែកកត្តាមួយទៀត គឺកត្តាជីវសាស្ត្រ ហៅថាតំណពូជជាដើម។

រីឯការព្យាបាល បើសិនយើងធ្វើកាន់តែឆាប់ កាន់តែប្រសើរ យើងព្យាបាលដោយប្រើថ្នាំ និងព្យាបាលដោយការស្តារនីតិសម្បទាមានន័យថា យើងបង្រៀនអ្នកជំងឺ ឱ្យចេះធ្វើការងារប្រចាំថ្ងៃ ឬឈានមករកសភាពដើមវិញ។ ជាទូទៅបញ្ហាផ្លូវចិត្តដទៃទៀត ត្រូវបានដោះស្រាយដោយការផ្តល់ប្រឹក្សា ឬវិធីសាស្ត្រធ្វើលំហាត់ដង្ហើម។ អ្នកជំងឺដេកសណ្តូកលើគ្រែ ឬឥដ្ឋ ផ្ចង់អារម្មណ៍ ដកដង្ហើម ចូលឱ្យវែងៗ-ជ្រៅៗហើយកុំទាន់បញ្ចេញភ្លាម ត្រូវរាប់១-២-៣ នៅក្នុងអារម្មណ៍។ បន្ទាប់មកបញ្ចេញខ្យល់មកវិញយឺតៗ ធ្វើដូច្នេះឱ្យបាន ១០នាទី ម្តង ឬ២ដងក្នុងថ្ងៃ ក៏កាន់តែប្រសើរ។ ប្រសិនបើវិធីនេះគ្មានប្រសិទ្ធភាព គាត់ត្រូវទៅរកវេជ្ជបណ្ឌិតឯកទេសវិកលវិទ្យា។

**អាគីប និងសំភី**



វេជ្ជ. ចក ធីតា អនុប្រធានកម្មវិធីជាតិសម្រាប់សុខភាពផ្លូវចិត្ត

Photo: P. Samphy

### កន្លែងព្យាបាល

**បើប្រិយមិត្តមានបញ្ហាផ្នែកផ្លូវចិត្ត ឬចង់ពិគ្រោះអំពីបញ្ហានេះ ប្រិយមិត្តអាចអញ្ជើញទៅគ្លីនិកធីតាគន្ធា នៅផ្ទះលេខ ៥៥៤B ផ្លូវ១៦៣ នៅរាជធានីភ្នំពេញ ឬទូរស័ព្ទលេខ: ០១១ ៩១៤ ៤២៦។**

ការកើនឡើងនៃអ្នកជំងឺអេដស៍នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅទូទាំងពិភព-លោកកំពុងតែធ្វើឱ្យមានក្តីព្រួយបារម្ភយ៉ាងគំហុកពីបណ្តារាជរដ្ឋាភិបាល អង្គការជាតិ និងអន្តរជាតិ ជាពិសេសក្រសួងសុខាភិបាល ដែលលោកខិតខំធ្វើយ៉ាងណាដើម្បីកាត់បន្ថយ និងបញ្ឈប់នូវការរីករាលដាលរបស់ជំងឺនេះ។ ជាមួយនេះដែរនៅប្រទេសកម្ពុជា ក្រសួង និងអង្គការមួយចំនួនបានកំពុងស្វះស្វែងរកជំនួយជាថ្នាំពន្យាជីវិត និងផ្តល់ឱ្យអ្នកជំងឺនៅតាមបណ្តាមណ្ឌលសុខភាព ឬមន្ទីរពេទ្យដែលមានអ្នកជំងឺអេដស៍ស្ថិតនៅ ដែលប៉ុន្មានឆ្នាំចុងក្រោយនេះ អត្រានៃអ្នកទទួលថ្នាំពន្យាជីវិតមានការកើនឡើងខ្ពស់នៅស្ទើរគ្រប់ខេត្ត-ក្រុងទាំងអស់ក្នុងប្រទេសកម្ពុជា។ ដើម្បីឱ្យកាន់តែយល់ច្បាស់អំពីថ្នាំពន្យាជីវិតនេះ អ្នកនាំសារសូមលើកយកនូវកិច្ចសំភាសន៍មួយជាមួយលោកវេជ្ជបណ្ឌិតវិន សំណាង ឯកទេសផ្នែករោគកុមារ និងជាអ្នកសម្របសម្រួលផ្នែកវេជ្ជសាស្ត្រនៃមន្ទីរពេទ្យបង្អែកជ័យជំនះ ខេត្តកណ្តាល ដែលមានខ្លឹមសារដូចខាងក្រោម :



Photo: S. Philong

អ្នកជំងឺអេដស៍ត្រូវការថ្នាំពន្យាជីវិតដើម្បីបន្តក្តីសង្ឃឹមក្នុងការរស់នៅបន្តទៅមុខទៀតពីព្រោះជីវិតគេពិតជាមានតម្លៃ និងសេចក្តីថ្លៃថ្នូរដូចអ្នកដទៃទៀតផងដែរ

# លោកវិន សំណាង :
# “ថ្នាំពន្យាជីវិតមានសារៈសំខាន់”


Photo: S. Philong

**លោកវិន សំណាង វេជ្ជ-បណ្ឌិតឯកទេសខាងរោគកុមារ និងជាអ្នកសម្របសម្រួលវេជ្ជសាស្ត្ររវាងពេទ្យរដ្ឋ និងឯកជន។ សព្វថ្ងៃលោកកំពុងធ្វើការនៅមន្ទីរពេទ្យបង្អែកជ័យជំនះ នៅស្រុកតាខ្មៅ ខេត្តកណ្តាល។**

**អ្នកនាំសារ : តើថ្នាំពន្យាជីវិតគឺជាអ្វី ?**

**លោកវេជ្ជបណ្ឌិត:** ថ្នាំពន្យាជីវិតជាថ្នាំមួយប្រភេទសម្រាប់ប្រឆាំងជាមួយនឹងវីរុស (មេរោគ) អេចអាយវី (HIV) ប៉ុន្តែមិនមែនមានន័យថា ជាថ្នាំសម្រាប់ព្យាបាលមេរោគអេដស៍ ឱ្យជាអស់នោះទេ។ វាគឺគ្រាន់តែជួយឱ្យអ្នកជំងឺមានសុខភាពល្អ ទទួលបានគុណភាពនៃជីវិត និងមានជីវិតរស់នៅបានយូរ។ ថ្នាំនេះក៏ជួយឱ្យអ្នកជំងឺទទួលទានអាហារបានច្រើនឡើងទម្ងន់ និងជួយធ្វើឱ្យប្រព័ន្ធការពារមានភាពខ្លាំង និងរីកលូតលាស់ឡើងវិញ ជាពិសេសអាចការពារមិនឱ្យមានជំងឺឱកាសនិយមផ្សេងៗចូលមកជ្រៀតជ្រែកក្នុងខ្លួនរបស់អ្នកជំងឺជាដើម។ ម្យ៉ាងទៀតថ្នាំនេះ ធ្វើឱ្យចំនួនវីរុស HIV នៅក្នុងខ្លួនឬឈាមរបស់អ្នកជំងឺមានកម្រិតទាប មានន័យថាថ្នាំអាចជួយកាត់បន្ថយចំនួនមេរោគ HIV ក្នុងខ្លួននៃអ្នកផ្ទុកមេរោគអេដស៍បាន។

**អ្នកនាំសារ : តើនៅក្នុងតំណាក់កាលណា ដែលអ្នកជំងឺត្រូវទទួលយកថ្នាំពន្យាជីវិតនេះ ?**

**លោកវេជ្ជបណ្ឌិត :** ដោយសារតែបច្ចេកទេសមានភាពទំនើបទាន់សម័យ យើងមានម៉ាស៊ីនសម្រាប់ពិនិត្យមើលសេដេកាត់ (CD4) ជូនអ្នកជំងឺអេដស៍បាន។ នៅពេលដែលអ្នកជំងឺពេញវ័យមានសេ-ដេកាត់ នៅក្រោម ២៥០ យើងអាចចាប់ផ្តើមផ្តល់ថ្នាំចំពោះគាត់។ ចំពោះកុមារវិញ យើងអាចផ្តល់ថ្នាំតាមកម្រិតសេដេកាត់នៃអាយុនីមួយៗ ដូចជាកាលណាគេអាយុក្រោម ១ឆ្នាំ និងមានសេដេកាត់ស្ថិតនៅក្រោម ២៥ភាគរយ។ កុមារៗ ដែលមានអាយុពី១ឆ្នាំ ទៅ៣ឆ្នាំ ហើយមានសេដេកាត់ស្ថិតនៅក្រោម ២០ភាគរយ និងកុមារដែលមានអាយុពី៣ឆ្នាំ ដល់៥ឆ្នាំ ដែលមានសេដេកាត់ក្រោម ១៥ភាគរយ។ ប៉ុន្តែចំពោះកុមារដែលមានអាយុចាប់ពី ៥ឆ្នាំទៅ ពេលខ្លះគេគិតថា វាមានកម្រិតដូចជាមនុស្សធំដែរដែលមានសេដេកាត់ក្រោម២៥០ គ្រូពេទ្យអាចឱ្យថ្នាំនេះបាន ព្រោះបើគិតជាភាគរយគឺស្ថិតនៅក្រោម ១៥ភាគរយដូចគ្នា។

**អ្នកនាំសារ: តើគេកំណត់អាយុអ្នកជំងឺប៉ុន្មានដែលអាចទទួលយកថ្នាំពន្យាជីវិតនេះបាន ?**

**លោកវេជ្ជបណ្ឌិត :** តាមពិតយើងមិនបានគិតអំពីរឿងអាយុឡើយសំខាន់ គឺឱ្យតែអ្នកជំងឺមានកម្រិតសេដេកាត់ ត្រូវទៅតាមកំណត់របស់រូបមន្ត (Guidelines) គឺគាត់អាចទទួលថ្នាំនេះបានហើយ។ ចំពោះកុមារវិញ ចាប់ពីថ្ងៃកើតរហូតដល់ ៦សប្តាហ៍ យើងមិនអាចដឹងថា តើគេមានជំងឺអេដស៍ ឬក៏មិនមាននោះទេ ប៉ុន្តែចាប់ពីអាយុ ៦សប្តាហ៍ ឬមួយខែកន្លះឡើងទៅ យើងអាចធ្វើតេស្តឈាមដឹងថាតើគេមានមេរោគអេដស៍ ឬអត់ហើយ។ ដូច្នេះការដែលយើងអាចចេញថ្នាំឱ្យបាន គឺនៅពេលកុមារមានលទ្ធផលឈាមបញ្ជាក់ថា គេមានមេរោគអេដស៍ និងកម្រិតនៃគ្រាប់ឈាមការពារក្នុងខ្លួនរបស់គេនោះមានការធ្លាក់ចុះខ្លាំង ឬល្មមទៅនឹងការកំណត់របស់រូបមន្ត (Guidelines)។ ប៉ុន្តែមានកុមារខ្លះអាយុក្រោម ១២ខែ យើងក៏អាចឱ្យថ្នាំពន្យាជីវិតគេបានដែរ គឺនៅពេលណាដែលយើងពិនិត្យឃើញថា ក្នុងខ្លួនគេ មានសេដេកាត់ក្រោម ២៥ភាគរយ។

## សេដេកាត់ជាអ្វី ?

**សេដេកាត់ (CD4) ជាកោសិកានៃប្រព័ន្ធការពាររាងកាយមនុស្ស។ ក្រុមសេដេកាត់នេះ ជាក្រុមកោសិកានៃប្រព័ន្ធការពារខ្លួន។ នៅក្នុងខ្លួនមនុស្សមានប្រព័ន្ធការពារផ្សេងៗគ្នាជាច្រើនទៀត ដែលប្រព័ន្ធទាំងនេះអាចប្រឆាំងទៅនឹងមេរោគមិនឱ្យរីករាលដាលបាន។ ចំពោះអ្នកផ្ទុកមេរោគអេដស៍ ប្រព័ន្ធសេដេកាត់ ជាកោសិកាប្រព័ន្ធការពាររាងកាយដែលមានលក្ខណៈពិសេសសម្រាប់មេរោគ HIV មានន័យថា វីរុសអេដស៍សំដៅសម្លាប់សេដេកាត់នេះ។**

**អ្នកនាំសារ: ថ្នាំពន្យាជីវិតនេះមានសារៈសំខាន់យ៉ាងណាចំពោះអ្នកជំងឺអេដស៍ដែរ ?**

**លោកវេជ្ជបណ្ឌិត:** ថ្នាំពន្យាជីវិតមានសារៈសំខាន់ណាស់ សម្រាប់អ្នកផ្ទុកវីរុស HIV និងអ្នកជំងឺអេដស៍ មិនថាចំពោះមនុស្សចាស់ ឬក្មេងទេ។ ថ្នាំនេះជួយស្តាបនាប្រព័ន្ធការពារនៅក្នុងរាងកាយរបស់អ្នកជំងឺអេដស៍ឱ្យវាមានកម្រិតខ្ពស់ឡើងវិញ ដូចជានៅពេលដែលគាត់លេបថ្នាំនេះ វាធ្វើឱ្យប្រព័ន្ធការពារសេដេកាត់របស់គាត់ មានកម្រិតខ្ពស់។ មួយវិញទៀតថ្នាំពន្យាជីវិតនេះ ជួយកាត់បន្ថយចំនួនមេរោគ HIV នៅក្នុងឈាម។ នៅពេលដែលអ្នកជំងឺ បានលេបថ្នាំនេះជាទៀងទាត់នោះ ក៏នឹងធ្វើឱ្យគាត់អាចចៀសផុតពីការឈឺជំងឺផ្សេងៗ មានជាអាទិ៍ដូចជា ជំងឺផ្សិត រមាស់ ឬជំងឺរាករូសជាដើម។ ជំងឺឱកាសនិយមតែងកើតឡើងទៅតាមកម្រិតនៃសេដេកាត់ មានន័យថា នៅពេលដែលអ្នកជំងឺលេបថ្នាំពន្យាជីវិត ចំនួនសេដេកាត់របស់គាត់នឹងកើនឡើង។ ដូច្នេះគាត់គឺអាចចៀសផុតពីជំងឺឱកាសនិយមទាំងនោះ។ ចំនុចសំខាន់មួយទៀតរបស់ថ្នាំពន្យាជីវិត គឺការប្រើប្រាស់សម្រាប់ស្ត្រីដែលមានផ្ទៃពោះ ដែលអាចជួយកាត់បន្ថយការចម្លងមេរោគពីម្តាយទៅកូន។ យើងអាចផ្តល់ថ្នាំជូនម្តាយនៅក្នុងពេលឆ្លងទន្លេ ក្នុងបំណងកាត់បន្ថយអត្រាការចម្លងពីម្តាយទៅកូនព្រោះថាម្តាយអាចចម្លងមេរោគទៅកូនបានច្រើនតំណាក់កាលដូចជានៅពេល ដែលគាត់មានផ្ទៃពោះ ពេលឆ្លងទន្លេ (គឺអាចមានដាច់រលាត់) និងពេលបំបៅដោះទៅដល់កូនជាដើម។

**អ្នកនាំសារ : បើនៅពេលដែលអ្នកជំងឺលេបហើយ មានប្រតិកម្មតើដោយសារអ្វី ?**

**លោកវេជ្ជបណ្ឌិត :** កត្តាទាំងនេះអាចកើតមានឡើង ដោយសារខ្លួនរបស់អ្នកជំងឺមិនទទួលយកថ្នាំនោះបាន។ វាមានន័យថា ធម្មតាខ្លួនយើងមានប្រព័ន្ធការពារ (អង់ទីគ័រ) តែនៅពេលដែលខ្លួនយើងមិនអាចទទួលយកបាននោះ វាបង្កើតជាជម្លោះធ្វើឱ្យមានប្រតិកម្មកើតឡើងពីព្រោះថ្នាំដែលយើងលេប អាចចាត់ទុកថា ជាប្រភេទអង់ទីសែនមួយដែរ។ ប្រសិនបើនៅពេលដែលអ្នកជំងឺលេបហើយមានប្រតិកម្មចំពោះថ្នាំមួយណា យើងអាចដកនូវមុខថ្នាំនោះចេញ និងសាកឱ្យគាត់លេបថ្នាំប្រភេទមួយទៀត។ ថ្នាំពន្យាជីវិតនេះមិនមែនចេះតែមានប្រតិកម្មទាំងអស់នោះទេ គ្រាន់តែថាថ្នាំខ្លះប្រតិ-កម្មដោយធ្វើឱ្យរមាស់នៅលើស្បែក។ ខ្លះធ្វើឱ្យអ្នកជំងឺរាករូស ចុកពោះ និងក្អួតជាដើម ដែលយើងអាចព្យាបាលបាន ប៉ុន្តែពេលខ្លះ ក៏អាចប្រតិកម្មរហូតដល់ស្លាប់ផងដែរ។ នៅក្នុងករណីដែលគាត់ប្រើប្រាស់ថ្នាំពន្យានេះ ហើយវាមានការគំរាមកំហែងដល់ជីវិតនោះ គឺគ្រូពេទ្យអាចបញ្ឈប់ដើម្បីធ្វើការជួយសង្គ្រោះគាត់ ឱ្យរួចជីវិតសិនបន្ទាប់មកយើងត្រូវគិតថា តើយើងគួរឱ្យគាត់ប្រើម្តងទៀតឬយ៉ាងណា? ។ ប៉ុន្តែបើគាត់លេបទៅគ្រាន់តែចេញជារមាស់បន្តិចបន្តួចទេនោះ យើងគ្រាន់តែឱ្យថ្នាំបំបាត់រមាស់ដោយរក្សាឱ្យគាត់ប្រើនូវថ្នាំពន្យាជីវិតនោះរហូតដដែល។

**អ្នកនាំសារ : នៅពេលប្រើប្រាស់ថ្នាំនេះ តើអ្នកជំងឺត្រូវតមអ្វីខ្លះ និងត្រូវប្រតិបត្តិខ្លួនបែបណា ?**

**លោកវេជ្ជបណ្ឌិត:** សម្រាប់នៅពេលប្រើប្រាស់ថ្នាំពន្យាជីវិតនេះ អ្វីដែលអ្នកជំងឺចាំបាច់ត្រូវប្រតិបត្តិ និងចៀសវាងនោះ មិនខុសពីការប្រតិបត្តិចំពោះជំងឺផ្សេងៗ មានដូចជា ជំងឺរលាកថ្លើម ឬមួយក៏ជំងឺមហារីកនោះទេ។ នៅពេលដែលអ្នកជំងឺអេដស៍ទទួលនូវថ្នាំពន្យាជីវិតនេះ អ្នកជំងឺដាច់ខាតមិនត្រូវជក់បារី និងផឹកស្រាឡើយព្រោះរបស់ទាំងអស់នេះជាកត្តាដែលជំរុញឱ្យសុខភាពរបស់អ្នកជំងឺ កាន់តែមានភាពទ្រុឌទ្រោម។ទាំងនេះគ្មានផលប្រយោជន៍សម្រាប់អ្នកជំងឺនោះទេ។ ម្យ៉ាងទៀតដែលតម្រូវឱ្យអ្នកជំងឺ គួរចៀសវាងដែរនោះ គឺគាត់គួរកាត់បន្ថយនូវការរួមភេទផ្តេសផ្តាស តែបើគាត់ចេះការពារឱ្យបានត្រឹមត្រូវ ហើយប្រើប្រាស់នូវស្រោមអនាម័យដោយត្រឹមត្រូវនោះ វាមិនសូវជាមានបញ្ហាចោទធ្ងន់ធ្ងរនោះទេ។

**អ្នកនាំសារ : នៅពេលដែលអ្នកជំងឺអេដស៍ ឈានមកដល់តំណាក់កាលលេបថ្នាំពន្យាជីវិតហើយ តែគាត់មិនទទួល តើគាត់នឹងមានផលលំបាកយ៉ាងណាខ្លះ ?**

...


Photo: S. Philong

ថ្នាំពន្យាជីវិតផ្តល់ដល់កុមារដែលអាចឱ្យគេមានសុខភាពល្អឡើងវិញ

October-2007 I.qxd 10/23/2007 2:09 PM Page 8



**លោកវេជ្ជបណ្ឌិត:** បើកម្រិតសេដេកាត់របស់គាត់ ត្រូវទទួលយកថ្នាំពន្យានៅគ្រប់មណ្ឌលសុខភាព ឬមន្ទីរពេទ្យ ដែលមានលទ្ធភាពផ្តល់ថ្នាំឱ្យគាត់ គឺគ្រូពេទ្យអាចផ្តល់ឱ្យគាត់បាន។ ប៉ុន្តែចំពោះករណីដែលគាត់ត្រូវដល់ពេលទទួលយកថ្នាំ តែគាត់មិនព្រមយក ឬលេបនោះជាសិទ្ធិសេរីភាពរបស់គាត់។ យើងមិនអាចបង្ខំគាត់ឱ្យទទួលយក១០០ភាគរយបានទេ។ ការសម្រេចចិត្តលេបថ្នាំ និងការឱ្យថ្នាំត្រូវតែមានការឯកភាពគ្នា និងមានការយល់ព្រមពីអ្នកឱ្យ និងអ្នកទទួល។ ប្រសិនបើគាត់មិនព្រមទទួលយកទេកម្រិតជំងឺរបស់គាត់អាចនឹងវិវឌ្ឍន៍ទៅរកសេចក្តីស្លាប់។ ជាទូទៅមុននឹងអ្នកជំងឺទទួលយកថ្នាំពន្យាជីវិតនេះ គឺតម្រូវឱ្យគាត់ទៅទទួលយកការប្រឹក្សា ជាមុនសិនពីថ្នាំពន្យាជីវិតនេះនិងអំពីរបៀបដែលអ្នកជំងឺអេដស៍ ត្រូវការពារ ពីព្រោះគាត់ត្រូវរស់នៅក្នុងចង្កោមគ្រួសារ។ អ្នកជំងឺត្រូវទៅទទួលយកនូវការប្រឹក្សាចំនួន៣លើក មុននឹងគ្រូពេទ្យសម្រេចផ្តល់ជូនគាត់។ នៅពេលដែលគាត់ចាប់ផ្តើមទទួលយកការពិភាក្សាចំនួន៣លើកនេះហើយ យើងអាចធ្វើការវាយតម្លៃ ដើម្បីឱ្យយើងដឹងថា តើការយល់ដឹងរបស់គាត់មានដល់កម្រិតណាដែរពីថ្នាំពន្យានេះ? ព្រោះថ្នាំនោះពុំមែនចង់ប្រើ គឺអាចប្រើបាន ហើយចង់ឈប់គឺឈប់នោះទេ។ ថ្នាំពន្យានេះ ត្រូវឱ្យអ្នកជំងឺប្រើអស់មួយជីវិតតែម្តង ហើយចំពោះកុមារ នៅពេលដែលគេធំពេញវ័យ គឺនៅតែប្រើថ្នាំនេះរហូតដល់ចាស់ គឺត្រូវប្រើប្រាស់ថ្នាំនេះអស់មួយជីវិត។


Photo: P. Samphy
កុមារមានផ្ទុកមេរោគត្រូវការការថែទាំ និងយកចិត្តទុកដាក់ពិសេស

**អ្នកនាំសារ:** តើថ្នាំនេះមានការប្រើប្រាស់ដោយរបៀបណា?

**លោកវេជ្ជបណ្ឌិត:** អ្នកជំងឺអេដស៍ត្រូវប្រើប្រាស់ថ្នាំនេះ មួយជីវិត មានន័យថា គឺលេបរហូតលុះដល់ចាស់។ អ្នកជំងឺ ទាមទារលេបថ្នាំក្នុងពេលវេលាយ៉ាងទៀងទាត់និងច្បាស់លាស់បំផុត។ បើគាត់ត្រូវលេបថ្នាំនេះព្រឹកម្តង និងល្ងាចម្តង គឺត្រូវកំណត់ពេលវេលា ច្បាស់លាស់មានន័យថា បើពេលព្រឹកលេបនៅម៉ោង៧ ល្ងាចក៏ត្រូវលេបម៉ោង៧ដែរ។ អ្នកផ្ទុកមេរោគអេដស៍ ត្រូវលេបបែបនេះរៀងរាល់ថ្ងៃ ពីព្រោះរយៈពេលនៃកម្រិតថ្នាំនៅក្នុងឈាម មាន ១២ម៉ោង។

**អាគីប**

### ថ្នាំពន្យាជីវិតមាន ៣ក្រុម ធំៗ

១. Reverse Transcriptase Inhibitors ២. Protease Inhibitors ៣. Fusion Inhibitors (T២០)។ គេចាប់ផ្តើមព្យាបាលដោយ (First line regimen) ដែលមានថ្នាំបីមុខ ហើយមុននឹងផ្លាស់ថ្នាំពីជួរទី១ ទៅជួរទី២ (Second line regimen) សូមប្រើជួរទី១ឱ្យអស់លទ្ធភាពសិន ពីព្រោះថ្នាំនេះមានជម្រើសតែ ២ជួរប៉ុណ្ណោះ។ សូមបងប្អូនទៅព្យាបាលជាមួយនឹងគ្រូពេទ្យដែលមានជំនាញច្បាស់លាស់។

# អត្រាឆ្លងអេដស៍ធ្លាក់ចុះ

អត្រារីករាលដាលនៃការឆ្លងជំងឺអេដស៍នៅប្រទេសកម្ពុជា បានធ្លាក់ចុះពី ១,២ ភាគរយនៅឆ្នាំ២០០៣ មកនៅត្រឹម០,៩ភាគរយ នៅឆ្នាំ២០០៦។

ថ្មីៗនេះ បើទោះបីជាប្រទេសកម្ពុជាបានប្រកាសអំពីអត្រាធ្លាក់ចុះនៃការឆ្លងរីករាលដាលនៃជំងឺអេដស៍ពី១,២ភាគរយ នៅឆ្នាំ២០០៣ មកនៅត្រឹម ០,៩ ភាគរយនៅឆ្នាំ២០០៦កន្លងទៅក្តី ក៏មន្ត្រីជំនាញនៅតែសម្តែងនូវការព្រួយបារម្ភដែលចំពោះការរីករាលដាលតាមរូបភាពនៃជំងឺអេដស៍ដែលគ្មានថ្នាំព្យាបាលនេះ។


Photo: P. Samphy
កិច្ចប្រឹងប្រែងត្រូវធ្វើបន្តដើម្បីកាត់បន្ថយគ្រោះថ្នាក់ពីជំងឺអេដស៍ដ៏សាហាវនេះ

បើយោងតាមការស្រាវជ្រាវនៃការឆ្លងមេរោគអេដស៍នាពេលបច្ចុប្បន្ននេះ គឺជាងពាក់កណ្តាល គឺជាការចម្លងពីប្តីទៅប្រពន្ធដែលជាមេផ្ទះ និង១ភាគ៣ពីម្តាយទៅកូន។

ចំពោះសេចក្តីព្រួយបារម្ភទៅលើភេទបុរសស្រលាញ់បុរសវិញ បើតាមការស្រាវជ្រាវមួយកាលពីអំឡុងឆ្នាំ២០០៥ អត្រាមានផ្ទុកមេរោគអេដស៍សម្រាប់ប្រភេទបុរសស្រឡាញ់បុរសនេះ មានដល់៥,១ភាគរយនេះ ដែលជាលទ្ធផលដែលគេអង្កេតនៅខេត្តបាត់ដំបង សៀមរាប ភ្នំពេញ និងបន្ទាយមានជ័យ-ល-។ ប៉ុន្តែលទ្ធផលមួយទៀតដែលគេធ្វើលំអិតនៅតែនៅភ្នំពេញឃើញថា អត្រាផ្ទុកមេរោគអេដស៍នៅក្នុងចំណោមបុរសប្រភេទនេះមានដល់ ៨,៧ភាគរយ។

ការស្រាវជ្រាវមួយទៀតបង្ហាញឱ្យឃើញថា ចំនួនស្ត្រីរកស៊ីផ្លូវភេទដោយប្រយោលមានការកើនឡើងទ្វេដង ពោលគឺនៅឆ្នាំ២០០៤ មានតែ ៦៨៩៦នាក់ប៉ុណ្ណោះ តែនៅពេលបច្ចុប្បន្ននេះ មានរហូតដល់ទៅ ១២៧៦២នាក់។ ចំណែកការប្រើប្រាស់ស្រោមអនាម័យជាមួយស្ត្រីប្រភេទនេះ គឺមានតែ ៤៨,២ភាគរយប៉ុណ្ណោះ។ នេះដោយសារតែឥរិយាបថរបស់បុរសច្រើនចាត់ទុកថា ស្ត្រីប្រភេទនេះថាជាសង្សារ ឬជាស្រីកំណាន់ចិត្ត ដូច្នេះទើបពួកគេមិនប្រើស្រោមអនាម័យ។

ប្រទេសកម្ពុជាចាប់ផ្តើមរកឃើញអ្នកផ្ទុកមេរោគអេដស៍តាំងតែពីឆ្នាំ១៩៩១ តាមរយៈអ្នកផ្តល់ឈាម។ ជំងឺដ៏កាចសាហាវនេះបានរីករាលដាលយ៉ាងខ្លាំងនៅឆ្នាំ១៩៩៤។ ហើយបើតាមរបាយការណ៍របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍បានឱ្យដឹងថា នៅកម្ពុជា មានអ្នកផ្ទុកនិងកើតជំងឺអេដស៍ចំនួន ១២ម៉ឺននាក់ហើយ។ ចំណែកកន្លែងដែលផ្តល់ប្រឹក្សាក្នុងការធ្វើតេស្តឈាម ដោយស្ម័គ្រចិត្តដើម្បីរកមេរោគអេដស៍កាលពីឆ្នាំ២០០៦ មាន ១៩០កន្លែង នៅទូទាំងប្រទេស។

ទិសដៅរបស់រដ្ឋាភិបាល គឺត្រូវផ្តល់ថ្នាំពន្យាជីវិតដល់អ្នកជំងឺអេដស៍គ្រប់ៗគ្នា និងនៅគ្រប់តំបន់-ខេត្ត-ក្រុងទាំងអស់។

មកទល់នឹងពេលនេះមានអ្នកជំងឺអេដស៍ជាង ១២០០០នាក់ហើយ ដែលបានទទួលថ្នាំពន្យាជីវិតនេះ។

រីឯរបាយការណ៍របស់ក្រសួងសុខាភិបាលវិញបង្ហាញថា នៅឆ្នាំ២០០៦ មានអង្គការជាតិ និងអន្តរជាតិចំនួន ១៦៦អង្គភាព បានចុះបំពេញបេសកកម្មគ្រប់រូបភាពក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ និងមេរោគអេដស៍នៅគ្រប់ខេត្ត-ក្រុងក្នុងប្រទេសកម្ពុជា។ ចំណែករបាយការណ៍របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍បានឱ្យដឹងទៀតថា គិតត្រឹមចុងខែមិថុនា ២០០៦នេះ អ្នកជំងឺអេដស៍ មានចំនួន ១៦៣៧៤នាក់ ក្នុងនោះ មានកុមារចំនួន ១៩៩៣នាក់។

**សំរង់ពីកាសែតរស្មីកម្ពុជា**





**ពលរដ្ឋប្រមាណជា ១០គ្រួសារ កំពុងរស់នៅប្រកបដោយភាពសប្បាយរីករាយក្រោមការជួយឧបត្ថម្ភ និងលើកទឹកចិត្តពីសំណាក់លោកបូជាចារ្យអូលីវីយេ ទោះបីជីវិតពួកគេធ្លាប់ត្រូវបានមើលងាយដោយសារផ្ទុកមេរោគអេដស៍ក៏ដោយ។ ផ្ទាំងជីវិតថ្មីត្រូវបានលាតត្រដាងប្រកបដោយភាពសុខសាន្តក្រោមក្តីសង្ឃឹមជាថ្មី។**

# អ្នកជំងឺអេដស៍ភ្នំវល្លិ៍ រីករាយនឹងជីវិតថ្មី


Photo: L. Sovanna
គេហដ្ឋានដ៏សមរម្យរបស់អ្នកជំងឺអេដស៍នៅមណ្ឌលសុខភាពជីវិត យ៉ូហាន ប៉ូល ទី២ (ភ្នំវល្លិ៍)

ផ្ទះប្រក់ស្បូវតូចៗ ប្រមាណជា១០ នៅជាប់ជើងភ្នំ មើលទៅហាក់ដូចជាមានភាពកណ្តោចកណ្តែងកណ្តាលព្រៃភ្នំស្ងាត់ជ្រងំ។ ចម្ងាយប្រមាណជា៥០ម៉ែត្រពីផ្ទះតូចៗនេះ មានដើមឈើជាច្រើនដើមដុះជាជួរៗ ប្រកបដោយសណ្តាប់ធ្នាប់ ដែលទាំងនោះ ជាដើមមន និងមានរោងមួយជាកន្លែងចិញ្ចឹមដង្កូវនាងនៅជិតនោះផងដែរ។

ចំការដាំមននេះបង្កើតឡើងតាំងពីឆ្នាំ២០០៤ក្នុងគោលបំណងផ្តល់ការងារដល់អ្នកផ្ទុកមេរោគអេដស៍ដែលកំពុងតែស្នាក់ក្នុងមណ្ឌលសុខភាព ជីវិត យ៉ូហាន ប៉ូលទី២ (ភ្នំវល្លិ៍) ក្រុងកែប។ អ្នកនាងនួន សារ៉េត វ័យ ៤៤ឆ្នាំ កម្មករចិញ្ចឹមដង្កូវនាង អ្នកថែរក្សា និងជាអ្នកដាំមន ក្នុងមណ្ឌល មានប្រសាសន៍ថា: "ការដាំមន និងការចិញ្ចឹមដង្កូវនាងនេះមិនមានការលំបាកណាស់ណានោះទេ ប៉ុន្តែយើងត្រូវយកចិត្តទុកដាក់ថែទាំផងទើបបានទិន្នផលល្អ។" បន្ទាប់ពីដាក់ចំណីដង្កូវនាងរួចរាល់ អ្នកនាងសារ៉េតក៏ដើរមកអង្គុយលើគ្រែចាស់មួយនៅពីខាងមុខផ្ទះតូចមួយ រួចក៏បន្តសំដីលាយទឹកភ្នែករលីងរលោងថា: "ខ្ញុំមានផ្ទុកនូវមេរោគអេដស៍ ៣ឆ្នាំហើយ ដោយសារឆ្លងពីប្តីខ្ញុំ។" គាត់បន្តថា គាត់មិនមានបំណងចាកចេញពីទីនេះទេព្រោះថាកន្លែងនេះបានផ្តល់ភាពកក់ក្តៅសម្រាប់គាត់ និងក្រុមគ្រួសារ។

អង្គុយនៅក្បែរនោះដែរ អ្នកស្រីង៉ែត វណ្ណៈ អាយុ៣៩ឆ្នាំ អ្នកផ្ទុកមេរោគអេដស៍តាំងពីឆ្នាំ១៩៩៣មក បានឱ្យដឹងពីអារម្មណ៍រីករាយរបស់គាត់ថា ទោះបីជាខ្លួនគាត់មានផ្ទុកនូវជំងឺមួយដ៏សាហាវ ដែលមិនអាចព្យាបាលបានក៏ដោយ ក៏មិនមានអ្នកមើលងាយ និងសើចចំអកឱ្យទៀតហើយ ព្រោះតែខ្ញុំបានមកនៅទីនេះ ហើយក៏មិនទៅណាទៀតដែរ។" អ្នកស្រីបានឱ្យដឹងទៀតថាកាលដែលគាត់រស់នៅស្រុកកំណើត មានអ្នកស្រុកនៅក្បែរៗនោះ មើលងាយសើចចំអក និងមិនហ៊ានមើលមុខរបស់គាត់ទេ ដោយសារពួកគេខ្លាចឆ្លងជំងឺ។


Photo: L. Sovanna
អ្នកជំងឺអេដស៍ផ្តល់សម្ភាសន៍យ៉ាងរីករាយព្រោះគាត់មានសង្ឃឹមហើយ

លោកម៉ៅ សាម៉ន ជាអ្នកទទួលខុសត្រូវនៅក្នុងមណ្ឌលនោះ មានប្រសាសន៍ឱ្យដឹងដែរថា: "គោលបំណងសំខាន់របស់យើង ក្នុងការបង្កើតការងារសម្រាប់រូបពួកគាត់នោះដោយសារយើងឃើញមានប្រជាជនជាច្រើនបានមើលងាយនិងស្អប់ខ្ពើមពួកគាត់ និងមានអ្នកខ្លះ មិនមានអាហារ និងកន្លែងស្នាក់នៅ។ ដូច្នេះយើងត្រូវជួយពួកគាត់ដើម្បីឱ្យមានកន្លែងស្នាក់នៅ និងមានការងារធ្វើ។"

អង្គុយផ្អែកជញ្ជាំងនៅលើគ្រែ និងដាក់កូនប្រុសតូចរបស់គាត់ នៅពីខាងមុខនោះដែរ អ្នកនាងសឹម ពៅ វ័យ ៣៩ឆ្នាំ មានប្រសាសន៍ដោយក្តុកក្តួលក្នុងចិត្តថា: "នៅពេលដែលគេពុំទាន់ដឹងថា ខ្ញុំមានមេរោគអេដស៍ ពួកគេនាំគ្នាមកទិញទំនិញរបស់ខ្ញុំគ្រប់ៗគ្នា តែនៅពេលដែលគេដឹង គឺកុំថាឡើយទិញ សូម្បីតែមុខក៏មិនមើលដែរ។" ស្ត្រីដែលមានកូន៣នាក់ ក្នុងបន្ទុក បានទទួលជំងឺដ៏សាហាវនេះនៅឆ្នាំ២០០៣ ពីប្តីរបស់គាត់ ប៉ុន្តែកូនរបស់គាត់មិនមានជំងឺនេះទេ។ អ្នកស្រីក៏ប្រាប់ថា ប៉ុន្តែគាត់មិនខឹងនឹងពួកគេទេ ដោយសារពួកគេមិនមានការយល់ដឹងច្បាស់អំពីការចម្លងមេរោគអេដស៍នេះ។

លោកម៉ៅ សាម៉ន ប្រាប់ឱ្យដឹងទៀតថា ក្រៅពីផ្តល់ការងារហើយ យើងមានផ្តល់ជាអង្ករ និងថវិកា ឱ្យពួកគាត់រៀងរាល់ខែផងដែរ។ លោកបន្ថែមថា ក្រុមគ្រួសាររបស់ពួកគាត់ម្នាក់ៗ ទទួលបានអង្ករខុសៗគ្នាតាមចំនួនសមាជិកនៅក្នុងគ្រួសារដោយគ្រួសារខ្លះ ទទួលបាន៥៦គីឡូក្រាម និងខ្លះទទួលបាន៥០គីឡូក្រាម និងថវិកាចំនួន ៥ម៉ឺនរៀល ក្នុង១ខែ។ លោកម៉ៅ សាម៉ន សង្កត់ធ្ងន់លើចំនុចមួយទៀតថា ការទទួលយកអ្នកជំងឺនៅទីនោះមានលក្ខខណ្ឌ គឺទាល់តែអ្នកជំងឺនោះមានជីវភាពក្រីក្រលំបាក និងមានគ្រួសារហើយ។

**អាគីប**

### ចំការក្នុងមណ្ឌលសុខភាពជីវិត យ៉ូហាន ប៉ូល ទី២

នៅក្នុងមណ្ឌល មានចំការមួយ ដែលនៅក្នុងនោះមានដើមមនចំនួន ២ម៉ឺនដើម សម្រាប់ឱ្យជាចំណីដល់ដង្កូវនាង ដែលដាំនៅលើផ្ទៃដី ២ហិចតា។ តាមរយៈសកម្មភាពកន្លងមក មណ្ឌលបានផលិតចេញជាសរសៃសូត្រដែលអាចលក់ទៅឱ្យរោងតម្បាញស្ពាន នៅព្រះសហគមន៍ចំការទៀងជាច្រើនដងរួចមកហើយ។ ក្នុងមួយគីឡូក្រាមសូត្រមានតម្លៃ ៣០ដុល្លារ ហើយ នៅក្នុងនោះ ក្នុងមួយខែៗ មណ្ឌលផលិតបានពី២ ទៅ៣គីឡូក្រាមនៃសរសៃ។ ចំពោះទៅថ្ងៃអនាគត មណ្ឌលមានគម្រោងថា នឹងបង្កើនផលិតផលឱ្យបានច្រើនជាងនេះទៅទៀត ដែលគេអាចនាំចេញយកទៅលក់នៅលើទីផ្សារក្នុងប្រទេសទាំងមូលផងដែរ។

October-2007 I.qxd  10/23/2007  2:09 PM  Page 10



## លោកបូជាចារ្យអ៊ុន សុន : "តើបេសកកម្មមានអត្ថន័យយ៉ាងដូចម្ដេចចំពោះខ្ញុំ?"


Photo: H. Sotheary

លោកបូជាចារ្យអ៊ុន សុន ដែលសព្វថ្ងៃ ទទួលខុសត្រូវនៅព្រះសហគមន៍កំពត បង្ហាញយោបល់ចំពោះទិវាបេសកកម្មពិភពលោកលើកទី១៨ ថា ក្រោយពេលព្រះយេស៊ូសោយទិវង្គត និងទទួលព្រះជន្មថ្មីដ៏រុងរឿង ក្រុមគ្រីស្តទូតបានបន្តបេសកកម្មរបស់ព្រះអង្គទៅទៀត ដោយមានព្រះវិញ្ញាណព្រះអង្គគង់នៅជាមួយផង។ យើងជាគ្រីស្តបរិស័ទបន្តមុខងារនេះតរហូតពីក្រុមគ្រីស្តទូតរហូតមកដល់សព្វថ្ងៃ។
ចំពោះខ្ញុំក្នុងឋានៈជាបូជាចារ្យ បេសកកម្មមានន័យថា ខ្ញុំយកចិត្តទុកដាក់បម្រើព្រះសហគមន៍ដោយយល់ពីសុខទុក្ខរបស់បងប្អូន ដឹងពីសេចក្ដីត្រូវការរបស់ពួកគេ ហើយរួមគ្នាដោះស្រាយជាមួយលោកអភិបាល ជាពិសេសបង្រួបបង្រួមបងប្អូនគ្រីស្តបរិស័ទ ថែរក្សាជំនឿបងប្អូន និងជួយណែនាំពីវិស័យព្រលឹងវិញ្ញាណ។ ជាក់ស្ដែងកន្លងមក ខ្ញុំយកពេលវេលាជាមួយបងប្អូនគ្រីស្តបរិស័ទរិះគិតអំពីព្រះបន្ទូល អធិដ្ឋាន ជួបជុំគ្នា និងប្ដូរយោបល់ដើម្បីពង្រឹងជំនឿឱ្យរឹងមាំ និងមានទំនុកចិត្ត និងសេចក្ដីស្រឡាញ់កាន់តែខ្លាំងឡើងៗ។ យើងទាំងអស់គ្នា រួមគ្នាជួយដល់បងប្អូនមានជំងឺដែលគ្មានលទ្ធភាពព្យាបាលខ្លួនឯង។ យើងសួរសុខទុក្ខអ្នកអស់សង្ឃឹម អ្នកក្រីក្រទាំងក្នុងព្រះសហគមន៍ និងទាំងក្នុងសង្គមដោយគ្មានការរើសអើងឋានៈ វណ្ណៈ ជាតិសាសន៍ ឬសាសនាណានោះទេ។
នៅថ្ងៃបេសកកម្ម ខ្ញុំសូមអង្វរព្រះជាម្ចាស់ឱ្យប្រទានកម្លាំង និងប្រទានពន្លឺដល់បងប្អូនទាំងអស់ដែលកំពុងបំពេញបេសកកម្មនៅគ្រប់ទីកន្លែងទាំងអស់។"

**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក :**
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់
បឹងព្រលិត ខណ្ឌ ៧មករា រាជធានី ភ្នំពេញ
Tel/Fax : (855) 23 224 120 ;
E-mail : csccambodia@gmail.com
Web: www.catholiccambodia.org
**ក្រុមប្រឹក្សាភិបាល :** លោកអភិបាល អេមីល ដេតម្បូ និងលោកអូមែរ ហ្ស៊ីរ៉ាល់ដូ ។
**ចាងហ្វាងការផ្សាយ :** លោកលី សុវណ្ណា ។
**រោងពុម្ព : ភ្នំពេញ។**

## សាររបស់សម្ដេចប៉ាបបេណេឌីក ទី១៦ សម្រាប់ទិវាបេសកកម្មពិភពលោកលើកទី ៨១ ( ព្រះសហគមន៍ទាំងអស់សម្រាប់ពិភពលោកទាំងមូល)

**បងប្អូនជាទីស្រឡាញ់ !**

នៅក្នុងឱកាសទិវាបេសកកម្មពិភពលោកឆ្នាំនេះ ខ្ញុំមានសេចក្ដីសោមនស្សរីករាយអញ្ជើញបងប្អូន ជាប្រជារាស្ត្ររបស់ព្រះជាម្ចាស់ រិះគិតអំពីសេចក្ដីត្រូវការចាំបាច់ និងសារៈសំខាន់នៃបេសកកម្មរបស់ព្រះសហគមន៍ ។

**"ព្រះសហគមន៍ទាំងអស់សម្រាប់ពិភពលោកទាំងមូល"** គឺជាប្រធានបទដែលត្រូវបានជ្រើសក្នុងទិវាបេសកកម្មពិភពលោកឆ្នាំនេះ ។ នៅក្នុងទិវានេះ ខ្ញុំសូមអញ្ជើញព្រះសហគមន៍នីមួយៗគ្រប់ទ្វីបទាំងអស់ ចាប់អារម្មណ៍ចំពោះតម្រូវការចាំបាច់ ដើម្បីធ្វើឱ្យបេសកកម្មរបស់ព្រះសហគមន៍កើតមានសាជាថ្មីនៅក្នុងសម័យទំនើបនេះ ដែលពោរពេញទៅដោយឧបសគ្គជាច្រើនដែលជំទាស់នឹងជំនឿ ។ ព្រះសហគមន៍ត្រូវបន្តជួយដល់អស់បងប្អូនដែលបានទទួលអគ្គសញ្ញាជ្រមុជទឹកឱ្យចេះឆ្លើយតបចំពោះការត្រាស់ហៅរបស់ព្រះជាម្ចាស់ ដោយធ្វើជាសាសនទូត ។ នេះគឺជាពេលវេលាមួយដ៏សំខាន់ដើម្បីម្នាក់ៗ បើកដួងចិត្តពឹងផ្អែកទៅលើឧបការគុណរបស់ព្រះជាម្ចាស់ ព្រោះព្រះអង្គពុំដែលបោះបង់ចោលប្រជារាស្ត្ររបស់ព្រះអង្គណាម្នាក់ឡើយ ដោយរួមទាំងព្រះវិញ្ញាណដ៏វិសុទ្ធណែនាំគេឱ្យបំពេញគ្រប់គម្រោងការសង្គ្រោះរបស់ព្រះអង្គ ។

ព្រះសហគមន៍បានយកចិត្តទុកដាក់ក្នុងការបម្រើមនុស្សជាតិ ដោយបន្តបេសកកម្មរបស់ព្រះយេស៊ូគឺណែនាំ និងប្រកាសដំណឹងល្អទៅតាមវប្បធម៌ និងសង្គមនីមួយៗ ។ ព្រះសហគមន៍នាំការសង្គ្រោះរបស់ព្រះជាម្ចាស់ ទៅដល់ប្រជាជនទាំងអស់ ដែលកំពុងរងទុក្ខវេទនា រងការអាម៉ាស់ ការសង្កត់សង្កិន ភាពក្រីក្រ អំពើហិង្សា និងការរំលោភសិទ្ធិមនុស្ស-ល- ។ ព្រះសហគមន៍មិនអាចបោះបង់បេសកកម្មជាសកលនេះបានទេ ព្រោះសម្រាប់ព្រះសហគមន៍ អ្វីទាំងអស់នេះមានឥទ្ធិពលចំពោះគ្នាទៅវិញទៅមកយ៉ាងខ្លាំង ។

ពិតណាស់ ! ព្រះសហគមន៍នីមួយៗ ចាប់តាំងពីចាប់ផ្ដើម បានទទួលនូវការត្រាស់ហៅដើម្បីបំពេញបេសកកម្មស្ដែងចេញតាមរយៈសេចក្ដីក្លាហានក្នុងការប្រកាសដំណឹងល្អ ដែលបង្ហាញពីសេចក្ដីស្រឡាញ់របស់អ្នកជឿចំពោះព្រះជាម្ចាស់ ។ សមាជិកនៃក្រុមអ្នកជឿ មិនមែនគ្រាន់តែសហការក្នុងការប្រកាសដំណឹងល្អនោះទេ គេត្រូវតែដឹងថា គេជាអ្នកណែនាំ និងទទួលខុសត្រូវ ។ បេសកកម្មដែលព្រះយេស៊ូប្រគល់ឱ្យក្រុមគ្រីស្តទូត គឺជាបេសកកម្មសម្រាប់យើងទាំងអស់គ្នា ។

សូមកុំភ្លេចថា ក្នុងបេសកកម្មនេះ "ការអធិដ្ឋាន"ជាសកម្មភាពដែលសំខាន់ជាងគេ ។ បងប្អូនជាទីស្រឡាញ់ ! ជាថ្មីម្ដងទៀត ខ្ញុំសូមអញ្ជើញបងប្អូនរួមគ្នាអធិដ្ឋាន **"ឱ ! ព្រះបិតាយើងខ្ញុំដែលគង់នៅស្ថានបរមសុខ"** នៅតាមព្រះសហគមន៍នីមួយៗ ។ ដូច្នេះព្រះរាជ្យរបស់ព្រះជាម្ចាស់នឹងយាងមកដល់ផែនដីនេះ ។

សូមព្រះនាងម៉ារីដែលរួមជាមួយព្រះសហគមន៍តាំងតែពីដើមរៀងមក ជួយណែនាំយើងខ្ញុំឱ្យចេះថែរក្សាសេចក្ដីស្រឡាញ់ដែលយើងខ្ញុំបានទទួលពីព្រះជាម្ចាស់ ។ សូមជួយយើងខ្ញុំឱ្យមានទឹកចិត្តក្លាហានធ្វើជាសាសនទូតដើម្បីប្រកាសដំណឹងល្អ និងធ្វើជាសាក្សីរបស់ព្រះជាម្ចាស់គ្រប់ពេលវេលាអស់ពេញមួយជីវិត ។

**ធ្វើនៅបុរីវ៉ាទីកង់ ២០០៧**

**សម្ដេចប៉ាប បេណេឌីក ទី១៦**



### ម៉ារី គីមឡេង : "ខ្ញុំអាចធ្វើសក្ខីភាពអំពីការសង្គ្រោះ ក្ដីស្រឡាញ់ និងធម៌មេត្តាករុណា"

អ្នកស្រីម៉ារី គីមឡេង សមាជិកអនុគណៈកម្មការពិធីបុណ្យនៃព្រះសហគមន៍សន្តយ៉ូសែប-ផ្សារតូច នៅរាជធានីភ្នំពេញ មានចំណាប់អារម្មណ៍ថា: "ខ្ញុំសូមកោតសរសើរ និងសូមអរព្រះគុណដល់ព្រះអម្ចាស់ជាព្រះបិតា ដែលព្រះអង្គបានប្រទានជីវិតដ៏ថ្លៃថ្នូរដល់ប្រជារាស្ត្ររបស់ព្រះអង្គ ហើយទ្រង់ក៏បានជ្រើសរើសខ្ញុំ ឱ្យធ្វើជាបុត្រធីតារបស់ព្រះអង្គផងដែរ ។ ព្រះយេស៊ូគ្រីស្តជាព្រះមាគ៌ា និងជាពន្លឺដែលបានបង្ហាញ និងបំភ្លឺឱ្យរូបខ្ញុំបានជឿ និងយល់កាន់តែច្បាស់ឡើងថា ក្នុងនាមជា គ្រីស្តបរិស័ទ ខ្ញុំអាចបំពេញ និងបន្តបេសកកម្មរបស់ព្រះគ្រីស្តតាមរយៈជីវិតប្រចាំថ្ងៃរបស់ខ្ញុំដើម្បីផ្សព្វផ្សាយដំណឹងល្អ តាមទីកន្លែងដែលខ្ញុំធ្វើការ ក៏ដូចជានៅតាមទីកន្លែង ដែលខ្ញុំរស់នៅ និងប្រកបរបរចិញ្ចឹមជីវិត ។ ខ្ញុំអាចធ្វើសក្ខីភាពដែរអំពី **"ការសង្គ្រោះ សេចក្ដីស្រឡាញ់ និងធម៌មេត្តាករុណា"** របស់ព្រះជាម្ចាស់ ដោយលះបង់ប្រយោជន៍ផ្ទាល់ខ្លួន និងទឹកចិត្តយ៉ាងស្មោះស្ម័គ្រ ហើយជួយយកអាសា និងផ្ដល់ការបំរើដល់អ្នកដទៃ ដែលកំពុងត្រូវការជំនួយជាចាំបាច់ ។ ទៅថ្ងៃអនាគតខាងមុខ ខ្ញុំក៏រំពឹង ហើយនិងសង្ឃឹមជានិច្ចថា នៅក្រោមការណែនាំ និងចាត់តាំងរបស់ព្រះសហគមន៍នៅប្រទេសកម្ពុជា ខ្ញុំក៏អាចបំពេញតួនាទីជាបេសកជន ហើយចេញទៅធ្វើជាសក្ខីភាពផ្សព្វផ្សាយដំណឹងល្អដើម្បីបម្រើបងប្អូន និងបម្រើព្រះសហគមន៍ផងដែរនៅគ្រប់ទីកន្លែងក្នុងពិភពលោកដើម្បីឱ្យបានគាប់នូវព្រះហឫទ័យ និងសេចក្ដីប្រាថ្នារបស់ព្រះជាម្ចាស់ ។"

### ជិន សាង : "បេសកកម្មមានអត្ថន័យសំខាន់ណាស់សម្រាប់ខ្ញុំជាគ្រីស្តបរិស័ទ"

លោកជិនសាង ប្រធានក្រុមយុវជននៅព្រះសហគមន៍បឹងទំពុននៅរាជធានីភ្នំពេញមានមតិដែរថា: បេសកកម្មមានអត្ថន័យសំខាន់ណាស់សម្រាប់ខ្ញុំជាគ្រីស្តបរិស័ទ ។ការបំពេញបេសកកម្មគឺមិនត្រឹមតែជាការធ្វើដំណើរពីប្រទេសមួយទៅប្រទេសមួយនោះទេ តែក្នុងប្រទេសយើង ភូមិយើង និងកន្លែងដែលយើងរស់ ក៏ជាកន្លែងដើម្បីបំពេញបេសកកម្មដ៏មានតម្លៃថ្លៃថ្លា ។ម្យ៉ាងទៀតការបំពេញសកម្មភាពជាមួយបងប្អូនរបស់យើង មានដូចជាសួរសុខទុក្ខអ្នកជំងឺនៅតាមមន្ទីរពេទ្យ តាមផ្ទះ និងកន្លែងនានាជុំវិញប្រទេស ការសួរសុខទុក្ខ អ្នកក្រីក្រ និងលេងជាមួយក្មេងៗ ជាសកម្មភាពដែលពោរពេញដោយអត្ថន័យសម្រាប់យើងជាគ្រីស្តបរិស័ទ ។



## ថ្ងៃអាទិត្យទី ២៩ ក្នុងរដូវធម្មតា (ថ្ងៃទី២១ តុលា ឆ្នាំ២០០៧)

### "ត្រូវតែអធិដ្ឋានជានិច្ច មិនត្រូវរសាយចិត្តឡើយ"

( លូកា ១៨,១-៨)

ព្រះយេស៊ូលើកចៅក្រមដែលមានចិត្តអាក្រក់គ្មានមេត្តា ទុកជានិមិត្តរូបអំពីព្រះជាម្ចាស់ ។ ស្ត្រីមេម៉ាយម្នាក់តែងមករំខានគាត់ រហូតទាល់តែគាត់សុខចិត្តកាត់ក្ដីឱ្យនាង កុំឱ្យនាងមករំខានទៀត ។ យ៉ាងណាមិញ យើងត្រូវរំខានព្រះបិតារហូតទាល់តែព្រះអង្គប្រោសប្រណីដល់យើងដែរ ។
ប៉ុន្តែយើងជាអ្នកជឿ តែងតែមានបទពិសោធន៍ថា ព្រះបិតាមិនសូវតបឆ្លើយតាមពាក្យអង្វរ និងសំណូមពររបស់យើងទេ ។ ដូច្នេះហេតុអ្វីបានជាយើងត្រូវតែអង្វរព្រះអង្គ បើព្រះអង្គមិនប្រោសប្រណីដូច្នេះ?
យើងត្រូវនឹកថា ព្រះបិតាមិនបម្រើយើងទេ គឺយើងទេតើដែលបម្រើព្រះអង្គវិញ ។ កុំស្មានថា ព្រះអង្គត្រូវប្រោសប្រទានតាមសំណូមពររបស់យើង បើគិតដូច្នេះ យើងប្រើព្រះអង្គធ្វើជាអ្នកបម្រើរបស់យើងវិញ ។ នៅពេលយើង



អធិដ្ឋាន មិនចាំបាច់សូត្រធម៌វែងច្រំដែលៗ ដូចជាសាសន៍ដទៃឡើយ គឺត្រូវសន្ទនា យ៉ាងស្និទ្ធស្នាលជាមួយព្រះបិតាដែលស្រឡាញ់យើង ។ ព្រះអង្គជ្រាបអ្វីៗដែលយើងត្រូវការ មុនពេលដែលយើងអង្វរព្រះអង្គទៅទៀត ។ នៅពេលយើងអធិដ្ឋានយើងមិនធ្វើឱ្យព្រះជាម្ចាស់ផ្លាស់ប្ដូរព្រះគម្រោងការរបស់ព្រះអង្គទេ តែពាក្យអធិដ្ឋាននេះនាំឱ្យយើងផ្លាស់ប្ដូរចិត្តគំនិតរបស់យើងទៅវិញ ដែលធ្វើឱ្យយើងសុខចិត្តផ្ញើជីវិតទាំងស្រុងទៅលើព្រះអង្គជាទីស្រឡាញ់របស់យើង ។
ព្រះបិតាប្រៀបដូចជាម្ដាយ ពេលណាឮកូនយំ គាត់តែងមកលួងលោមកូនឱ្យឈប់ស្រក់ទឹកភ្នែកទៀតទៅ ។ យ៉ាងណាមិញ ព្រះបិតាទ្រង់ព្រះសណ្ដាប់អ្នកដែលផ្ញើជីវិតលើព្រះអង្គដោយការទុកចិត្ត ។

## ថ្ងៃអាទិត្យទី ៣០ ក្នុងរដូវធម្មតា (ថ្ងៃទី២៨ តុលា ឆ្នាំ២០០៧)

### "ព្រះជាម្ចាស់ប្រោសអ្នកទារពន្ធឱ្យបានសុចរិត"

( លូកា ១៨,៩-១៤)

នៅថ្ងៃនេះ ព្រះយេស៊ូរៀបរាប់ព្រះបន្ទូលជាប្រស្នា ថែងអំពីមនុស្សពីរនាក់ឡើងអធិដ្ឋានក្នុងព្រះវិហារ ។ ម្នាក់ជាមនុស្សល្អត្រឹមត្រូវកាន់តាមវិន័យរបស់ព្រះជាម្ចាស់សព្វគ្រប់ និងបានសន្សំបុណ្យជាច្រើន ។ គាត់មិនអួតខ្លួនទេ ពីព្រោះគាត់ជាអ្នកកាន់ធម៌យ៉ាងល្អបំផុត ។ គាត់អរព្រះគុណព្រះជាម្ចាស់ដោយគាត់ជាមនុស្សត្រឹមត្រូវ ។ គាត់ពុំសុំអ្វីពីព្រះអង្គឡើយព្រោះគាត់មិនត្រូវការព្រះអង្គសង្គ្រោះគាត់ទេ ។ ចំណែកម្នាក់ទៀតជាអ្នកទារពន្ធ ។ គាត់ពិតជាមនុស្សខិលខូច តែងតែហូតពន្ធហួសកម្រិត និងកេងប្រវ័ញ្ច-ល- ។ គាត់មិនហ៊ានងើបមុខទៅរកព្រះជាម្ចាស់ទេពីព្រោះគាត់ដឹងខ្លួនថា គាត់គឺជាអ្នកមានបាបច្រើនណាស់ ។ គាត់អង្វរដោយអស់ពីចិត្តថា "ព្រះជាម្ចាស់អើយ! សូមអាណិតមេត្តាខ្ញុំផង!។" ព្រះយេស៊ូមានព្រះបន្ទូលថា ព្រះជាម្ចាស់បានប្រោសអ្នកបាបនេះឱ្យបានសុចរិត ។ រីឯអ្នកបុណ្យនោះមិនបានសុចរិតទេ ។
ហេតុអ្វីបានជាព្រះជាម្ចាស់ប្រព្រឹត្តដូច្នេះ?
អ្នកខាងគណៈផារីស៊ីមិនត្រូវការអ្វីពីព្រះជាម្ចាស់សោះ ។ គាត់ស្មានថា ខ្លួនត្រូវតែទទួលរង្វាន់ ពីព្រោះខ្លួនគាត់គឺជាអ្នកមានបុណ្យ ។ ប៉ុន្តែគាត់ក៏ភ្លេចថា ការសង្គ្រោះជាព្រះអំណោយទានពីព្រះជាម្ចាស់ មិនមែនមកពីបុណ្យកុសល



របស់មនុស្សទេ ។ មនុស្ស! ទោះជាមានបុណ្យយ៉ាងណាក៏ដោយ ក៏មិនអាចទាមទារទទួលព្រះជន្មផ្ទាល់របស់ព្រះជាម្ចាស់បានឡើយ គឺមានតែអ្នកទទួលស្គាល់នូវសេចក្ដីត្រូវការរបស់ខ្លួន ដែលអាចទទួលព្រះជន្មព្រះអង្គបាន ។ ប៉ុន្តែត្រូវប្រយ័ត្នផងដែរ កុំស្មានថា ត្រូវតែធ្វើអំពើបាប ទើបព្រះអង្គសង្គ្រោះយើងនោះ ។ មិនមែនទេ! យើងត្រូវយកចិត្តទុកដាក់នឹងការប្រព្រឹត្តនូវអំពើល្អ ដើម្បីបញ្ជាក់ជំនឿរបស់ខ្លួន ។ ប៉ុន្តែខ្លួនយើងត្រូវដឹងថា អំពើល្អមិនអាចសង្គ្រោះមនុស្សបាននោះឡើយ គឺមានតែការផ្ញើជីវិតទាំងស្រុងលើព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចសង្គ្រោះមនុស្សបាននោះ ។

**សូមថ្លែងអំណរគុណដល់ជំនួយរបស់ក្រុមការងារមណ្ឌលវប្បធម៌កាតូលិកនៅកម្ពុជា !**

# លោកបូជាចារ្យអែននីរីកូបន្សល់សៀវភៅទស្សនវិជ្ជាជាកេរមរតកមុននឹងចាកចេញ



Photo: P. Samphy

**លោកបូជាចារ្យអែននីរីកូ ជនជាតិអ៊ីតាលី បានមកនៅប្រទេសកម្ពុជានៅឆ្នាំ២០០២។ ក្នុងអំឡុងពេលស្នាក់នៅនេះ លោកបានបំពេញនូវការងារជាច្រើនជាប្រយោជន៍ដល់ព្រះសហគមន៍ និងសង្គមកម្ពុជា។**

លោកបូជាចារ្យអែននីរីកូ បានមករស់នៅស្រុកខ្មែរអស់រយៈពេលជាង ៥ឆ្នាំ បន្ទាប់ពីលោកបានទទួលនូវអគ្គសញ្ញាតែងតាំងជាបូជាចារ្យនៅឆ្នាំ១៩៩៨។

ទោះបីថ្មីៗនេះ លោកបានចាកចេញពីស្រុកខ្មែរហើយក៏ដោយ តែក្នុងខណៈពេលដែលលោកបានមកស្នាក់នៅក្នុងប្រទេសខ្មែរ លោកក៏បានបំពេញនូវភារកិច្ចជាច្រើនក្នុងតួនាទីជាអ្នកបម្រើព្រះសហគមន៍ដែលព្រះជាម្ចាស់បានផ្តល់ភារកិច្ចនេះសម្រាប់រូបលោក ។

ទោះបីជាមានរវល់ទៅនឹងការគ្រប់គ្រងមណ្ឌលនិស្សិត លោកក៏នៅបានឆ្លៀតឱកាសមកចាប់អារម្មណ៍ ចំពោះការងារបកប្រែសៀវភៅមួយក្បាលដ៏មានសារៈសំខាន់ផងដែរ ។ ក្នុងទឹកមុខញញឹម និងលើកបង្ហាញសៀវភៅទស្សនវិជ្ជាដែលមានចំណងជើងថា "គ្រឹះរបស់ទស្សនវិជ្ជា" លោកបូជាចារ្យមានប្រសាសន៍ប្រាប់ពីមូលហេតុដែលនាំឱ្យលោកចាប់អារម្មណ៍ចំពោះការនិពន្ធ និងបកប្រែនូវសៀវភៅនេះថា : "ខ្ញុំធ្វើការងារនេះដោយសារមើលឃើញអំពីកង្វះខាតនូវឯកសារក្នុងការសិក្សា និងស្រាវជ្រាវជាច្រើន ។ ម្យ៉ាងទៀត គ្រាន់តែ ៣ឆ្នាំ ដែលខ្ញុំមកនៅ ឃើញថា និស្សិតខ្មែរនៅខ្វះឯកសារក្នុងការសិក្សាស្រាវជ្រាវជាច្រើន ។" លោកបន្តទៀតថាកម្មវិធីនេះពុំមែនលោកដែលជាអ្នកចាប់ផ្តើមឡើយ គឺលោកបូជាចារ្យកាង អ៊ីនហ៊្គីន ជាអ្នកចាប់ផ្តើមកិច្ចការនេះជាមួយ និងគ្រូ ៥នាក់ នៅសកលវិទ្យាល័យ ភូមិន្ទភ្នំពេញខាងផ្នែកចិត្តវិទ្យា ។ ប៉ុន្តែលោកអ៊ីនហ៊្គីន ត្រូវទៅរៀននៅប្រទេសសីរីលង្កា ទើបសុំឱ្យលោកជួយបន្ត ។

ទស្សនវិជ្ជា ជាមុខវិជ្ជាមួយដែលសំខាន់ ជាពិសេសគ្រប់បូជាចារ្យកាតូលិកទាំងអស់ត្រូវតែរៀន ។ ព្រះជាម្ចាស់តែងតែប្រើពាក្យពេជន៍ និងរាងកាយនៃមនុស្សដើម្បីសម្តែងព្រះអង្គតាមរយៈព្រះយេស៊ូដែលប្រសូតមកជាមនុស្ស និងផ្តល់តម្លៃដល់មនុស្ស ឱ្យគ្រប់លក្ខណៈទាំងគំនិត រាងកាយ និងពាក្យសំដី ។

ជាមួយនឹងសំឡេងសើចក្អឹកៗ លោកបូជាចារ្យអ៊ីតាលីរូបនេះក៏បន្តថា លោកចាប់អារម្មណ៍ចំពោះមុខវិជ្ជានេះដោយសារវាជាមុខវិជ្ជាដែលផ្តោតទៅរកសេចក្តីពិតតែម្តងដើម្បីជួយដល់អ្នកវិទ្យាសាស្ត្រឱ្យធ្វើការស្រាវជ្រាវ និងស្វែងរកនូវមុខជំនាញរបស់មនុស្ស ។ លោកនិយាយឱ្យដឹង ពីអត្ថប្រយោជន៍នៃសៀវភៅនេះថា សៀវភៅទស្សនវិជ្ជានេះ គឺជួយដល់យុវជនយុវនារីជាទូទៅ និងប្រៀបដូចជាឧបករណ៍មួយ ជួយដល់កូនខ្មែរឱ្យពួកគេស្វែងយល់អត្ថន័យជីវិត និងសេចក្តីពិត ។ លោកបន្ថែមដោយបញ្ចេញនូវភាពសប្បាយរីករាយផងដែរថា ការធ្វើការដើម្បីសៀវភៅនេះ គឺជួយលោក ឱ្យយល់ច្បាស់និងស៊ីជម្រៅពីវប្បធម៌ខ្មែរច្រើន ដោយសារការជ្រើសរើសពាក្យត្រូវស៊ីសង្វាក់ជាមួយនឹងប្រពៃណីខ្មែរច្បាស់មែនទែន ដែលការងារនេះ ទាមទារនូវការស្រាវជ្រាវច្រើន ។ សៀវភៅនេះបែងចែកជា បីផ្នែក គឺទស្សនវិជ្ជាជាអ្វី? ទស្សនវិជ្ជាភ្ជាប់ជាមួយធម្មជាតិ និងទស្សនវិជ្ជាជាមួយសាសនា ដើម្បីធ្វើការរៀបចំទ្រឹស្តីគោលការណ៍ និងសីលធម៌មិនៅក្នុងគោលលិទ្ធិ ។

លោកមានប្រសាសន៍ឱ្យដឹងដែរថា: "ចំពោះខ្លួនខ្ញុំផ្ទាល់របៀបដែលជួយដល់មនុស្ស គឺការស្វែងរកសេចក្តីពិត និងអត្ថន័យនៃជីវិតរបស់ខ្លួន ។ ដូច្នេះខ្ញុំគិតថា ទស្សនវិជ្ជាអាចជួយដល់មនុស្ស ដើម្បីស្វែងរកនូវចម្លើយត្រឹមត្រូវមួយ ឬក៏ចេះដាក់សំណួរមួយដ៏ត្រឹមត្រូវចំពោះខ្លួនឯង ។ ខ្ញុំដូចបូជាចារ្យជាទូទៅដែរ របៀបដែលប្រសើរជាងគេក្នុងការជួយមនុស្ស គឺជួយឆ្លើយនូវសំណួរដែលទាក់ទងនឹងអត្ថន័យជីវិតរបស់ខ្លួន ។"

ការធ្វើការជាមួយសៀវភៅនេះដែរ លោកក៏ជួបប្រទះនូវការពិបាក ពីព្រោះពាក្យខ្លះនៅក្នុងភាសាខ្មែរ គឺអត់មាន ហើយទ្រឹស្តីដើមចេញពីវប្បធម៌គ្រិស្តសាសនា តែត្រូវធ្វើការបកប្រែជាវប្បធម៌ពុទ្ធសាសនា ។

រយៈពេលនៃការរៀបចំសៀវភៅនេះ គឺចំណាយពេលអស់ជិតមួយឆ្នាំ ហើយមានធ្វើការបោះពុម្ពចំនួន ជាង ១០០០ក្បាល សម្រាប់ធ្វើការប្រើប្រាស់ជាសាធារណៈតែម្តង ដែលពេលសព្វថ្ងៃនេះ សៀវភៅមានដាក់លក់នៅតាមបណ្ណាគារមួយចំនួនក្នុងទីក្រុងភ្នំពេញ ។

**ធារី និងអាគីប**

## គម្រោងព្រះសហគមន៍

- **ថ្ងៃទី១៦-១៨ តុលា : ប្រជុំបូជាចារ្យ និងបងស្រីនៅព្រះសហគមន៍សៀមរាប ដើម្បីរិះគិតអំពីសកម្មភាពការងាររបស់ព្រះសហគមន៍ប្រចាំនៅភូមិភាគបាត់ដំបង។**
- **ថ្ងៃទី១-៣០ តុលា : ព្រះសហគមន៍ក្រុងព្រះសីហនុរៀបចំការអធិដ្ឋានតាមផ្ទះគ្រីស្តបរិស័ទ។**

## ស្នាដៃថ្មីចេញផ្សាយ!




**មណ្ឌលវប្បធម៌កាតូលិកកម្ពុជា មានបោះពុម្ពផ្សាយសៀវភៅប្រវត្តិសាស្ត្រសង្ខេបនៃប្រទេសកម្ពុជា ជាស្នាដៃនិពន្ធរបស់លោកបូជាចារ្យ ហ្វ្រង់ស្វ័រ ប៉ុងស្វដ៍ ដែលមានបីភាសា គឺ ខ្មែរ បារាំង និងអង់គ្លេស។ ប្រសិនបើប្រិយមិត្តមានចំណាប់អារម្មណ៍ សូមទំនាក់ទំនងមកទូរស័ព្ទ : ០២៣ ២១១ ២៥៣។ សូមអរគុណ!**

## មណ្ឌលអ្នកជំងឺអេដស៍

**បងប្រុសនៃក្រុមសាសនទូតមេត្តាករុណា !**

**សូមជម្រាបដំណឹងបងប្អូនថា : "ផ្ទះនៃក្តីសង្ឃឹម" មានទទួលថែរក្សាអ្នកជំងឺអេដស៍ជាបុរសភេទដោយមិនគិតថ្លៃ។ ដូច្នេះបើបងប្អូនបានស្គាល់អ្នកជំងឺអេដស៍បុរសដែលត្រូវការនូវសេវាខាងលើ សូមទាក់ទងមកក្រុមបងប្រុសនៃក្រុមសាសនទូតមេត្តាករុណានៅភូមិត្រពាំងសាលា សង្កាត់ពងទឹក ខណ្ឌដង្កោ ក្រុងភ្នំពេញ ឬទូរស័ព្ទលេខ : ០១២ ៩៥៩ ៨១៨។**

## សេវាកម្មជាទីគាប់ចិត្ត!

**ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក មានបម្រើសេវាកម្មបំប្លែងពីកាសែតវីដេអូ VHS ទៅ VCD និង DVD។ បំប្លែងពីកាសែតម៉ាញ៉េទៅជា CD និង MP3 និងមានទទួលធ្វើការថតចម្លង CD VCD និងDVD គ្រប់ប្រភេទផងដែរ។ គ្រប់សេវាកម្មទាំងនេះនឹងធ្វើក្នុងតម្លៃសមរម្យ។ សូមលោកអ្នកទំនាក់ទំនងតាមទូរស័ព្ទ : ០១២ ៣៧៧ ៤៦០។**

**មណ្ឌលផ្សព្វផ្សាយព័ត៌មានកាតូលិក មានចេញលក់នូវស៊ីឌីចម្រៀងវ៉ុលទី៦ ថ្មី ដែលពិពណ៌នាអំពីព្រះនាងម៉ារីឡើងស្ថានបរមសុខ និងចម្រៀងកោតសរសើរព្រះនាង។ តម្លៃក្នុងមួយ ស៊ីឌីគឺ ៨ ០០០រៀលតែប៉ុណ្ណោះ។ ប្រសិនលោកអ្នកចាប់អារម្មណ៍ សូមទំនាក់ទំនងតាមទូរស័ព្ទ : ០១២ ២៤៤ ៧៧៨។**